កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# ការផ្ទេរមុខងារក្នុងវិស័យអប់រំក្នុងខេត្តបាត់ដំបង

## មេរៀនដែលទទួលបានពីការអនុវត្ត



# មាតិកា


សង្ខេបសេចក្តី ..... 4
១. ការណែនាំ ..... 6
១.១ គោលបំណង និងសាវតា ..... 6
១.២ វិធីសាស្ត្រ និងដែនកំណត់ ..... 7
១.៣ គ្រោងនៃរបាយការណ៍ ..... 8
២. ក្របខណ្ឌច្បាប់ ..... 9
២.១ គោលការណ៍ណែនាំគោលនយោបាយសំខាន់ៗ៖ គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ ..... 9
២.២ ឧបករណ៍ច្បាប់សំខាន់ៗ៖ អនុក្រឹត្យលេខ ១៨២-១៨៤ អនក្រ.បក ..... 10
២.៣ បទប្បញ្ញត្តិ/សេចក្តីណែនាំរដ្ឋបាល ..... 11
២.៤ ការសង្កេត និងការវាយតម្លៃ ..... 14
៣. ស្ថាប័នគាំទ្រ ..... 15
៣.១ មន្ទីរអប់រំយុវជន និងកីឡាខេត្ត ..... 15
៣.២ ចាត់ការគ្រប់គ្រងធនធានមនុស្សខេត្ត ..... 17
៣.៣ មន្ទីរមុខងារសាធារណៈខេត្ត ..... 19
៣.៤ រដ្ឋបាលក្រុង/ស្រុក ..... 19
៣.៥ ការសង្កេត និងការវាយតម្លៃ ..... 25
៤. មេរៀនដែលបានសិក្សា និងអនុសាសន៍ ..... 26
៤.១ មេរៀន ..... 27
៤.២ អនុសាសន៍ ..... 31
ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះមន្ត្រីដែលបានសម្ភាសន៍ ..... 34

ឧបសម្ព័ន្ធទី២៖ សិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ............................................ 36
ឧបសម្ព័ន្ធទី៣៖ បញ្ជីបញ្ហាប្រឈម និងសំណូមពរ ................................................................. 40
ឧបសម្ព័ន្ធទី៤៖ សង្ខេបសេចក្តីនៃការស្វែងយល់ពីតម្រូវការសិក្សា................................................ 51

# សង្ខេបសេចក្តី

របាយការណ៍នេះពិនិត្យនូវដំណើរការអនុវត្តនៃមុខងារអប់រំដែលបានប្រគល់ (ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដល់រដ្ឋបាលស្រុក/ក្រុង ក្នុងខេត្តបាត់ដំបង យោងតាមអនុក្រឹត្យលេខ ១៨២-១៨៤ ចេញកាលពីខែធ្នូ ឆ្នាំ២០១៩។ ការត្រួតពិនិត្យគឺផ្អែកលើការសង្កេតផ្ទាល់ ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗនៃវិស័យនេះនៅថ្នាក់ខេត្ត និងកម្រិតរដ្ឋបាលក្រុង ស្រុក និងការវិភាគនៃបទប្បញ្ញត្តិ/គោលការណ៍ណែនាំដែលពាក់ព័ន្ធ។ របាយការណ៍នេះក៏ពិនិត្យមើលពីស្ថាប័នគាំទ្រដែលចាំបាច់សម្រាប់ការអនុញ្ញាតឱ្យរដ្ឋបាលក្រុង ស្រុក អនុវត្តមុខងារអប់រំដែលបានប្រគល់ដោយជោគជ័យ។ ផ្អែកលើការត្រួតពិនិត្យនេះ របាយការណ៍បានសង្ខេបមេរៀនសំខាន់ៗដែលបានមកពីការប្រគល់មុខងារទៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង និងផ្តល់នូវអនុសាសន៍គោលនយោបាយពាក់ព័ន្ធសម្រាប់ការដាក់ចេញនូវបែបបទនៃការប្រគល់ក្នុងវិស័យអប់រំទៅកាន់ខេត្តផ្សេងទៀតនៃប្រទេស។

ការប្រើប្រាស់បែបបទនៃការប្រគល់ក្នុងការផ្ទេរមុខងារវិស័យអប់រំទៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង គឺជាគំនិតផ្តួចផ្តើមសាកល្បងមួយៈ សម្រាប់ខេត្តផ្សេងៗទៀត បែបបទនៃការធ្វើប្រតិភូកម្មត្រូវបានប្រើប្រាស់។ ជាការកត់សម្គាល់និងអាចសង្កេតបាន ការប្រគល់មុខងារអប់រំមិនបានធ្វើឱ្យសេវាអប់រំក្នុងវិស័យនេះចុះខ្សោយនោះទេ។ សរុបមក អ្នកចូលរួមក្នុងការសិក្សានេះបានទទួលយកតួនាទី និងការទទួលខុសត្រូវថ្មីដែលភ្ជាប់មកជាមួយមុខងារដែលបានប្រគល់។ ជាការជាក់ស្តែង ដំណើរការផ្លាស់ប្តូរបែបនេះនឹងរួមបញ្ចូលបញ្ហាប្រឈម និងឧបសគ្គដែលនឹងត្រូវបានដោះស្រាយ។

ទីមួយ គោលការណ៍ណែនាំ និងសេចក្តីណែនាំផ្នែករដ្ឋបាលកាន់តែមានភាពច្បាស់លាស់គឺត្រូវការជាចាំបាច់ដើម្បីចង្អុលបង្ហាញដល់រដ្ឋបាលក្រុង ស្រុក។ ការអនុវត្តផ្សេងគ្នាពីបណ្តារដ្ឋបាលក្រុង ស្រុកបានបញ្ជាក់ថា មានការណែនាំមិនច្បាស់លាស់ ពេលខ្លះផ្ទុយគ្នា ដូចជារបៀបប្រើប្រាស់ត្រា ការស្នើសុំឈប់សម្រាក ឬរបៀបចេញ/កែសម្រួលនីតិវិធីរដ្ឋបាលនៅក្នុងការិយាល័យអប់រំជាដើម។ ទីពីរ សម្រាប់ដំណាក់កាលអន្តរកាល យន្តការគាំទ្រគឺត្រូវការជាចាំបាច់នៅថ្នាក់ខេត្ត ដែលអាចឆ្លើយតបបានទាន់ពេលវេលាទៅនឹងសំណួររបស់រដ្ឋបាលក្រុង ស្រុក ដើម្បីសម្របសម្រួលការទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ស្រុក។ ទីបី ការលើកកម្ពស់ការយល់ដឹងដ៏ទូលំទូលាយ និងការចែករំលែកព័ត៌មានអំពីការផ្ទេរមុខងារវិស័យអប់រំ ហើយការជាប់ពាក់ព័ន្ធត្រូវបានបានធ្វើឡើងនៅថ្នាក់ស្រុក និងថ្នាក់ឃុំ។ ក្រៅពីនេះតម្រូវការដើម្បីយល់ដឹង ការរៀបចំថ្មីៗ ក្រៅពីតម្រូវការក្នុងការស្វែងយល់អំពីការរៀបចំថ្មី អ្នកអនុវត្តផ្ទាល់ និងអ្នកទទួលផលនៃដំណើរការផ្ទេរ (ដូចជាមន្ត្រីតាមផ្នែក មន្ត្រីដទៃទៀតនៃរដ្ឋបាលក្រុង ស្រុក សមាជិកក្រុមប្រឹក្សា។ល។) ចាំបាច់ត្រូវ

ជឿជាក់អំពីអត្ថប្រយោជន៍ ដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរួមចំណែកក្នុងបរិបទថ្មីនៃការផ្តល់សេវាអប់រំដែលជាផ្នែកមួយនៃប្រព័ន្ធរបស់រដ្ឋបាលឯកភាព។ ទីបួន សៀវភៅណែនាំបច្ចេកទេសបណ្តុះបណ្តាលស្តីពីមុខងារអប់រំត្រូវបង្កើតឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយសាររដ្ឋបាលក្រុង ស្រុកកំពុងទន្ទឹងរងចាំឯកសារនេះ ដូច្នេះពួកគាត់អាចយកទៅអនុវត្តលើទំនួលខុសត្រូវថ្មីប្រកបដោយទំនុកចិត្តខ្ពស់។ ជាចុងក្រោយ ការកសាងសមត្ថភាពគឺនៅតែជាគន្លឹះនៃភាពជោគជ័យ។ មន្ត្រីរដ្ឋបាលក្រុង ស្រុកនៅតែថ្មី មិន ត្រឹមតែលើមុខងារអប់រំប៉ុណ្ណោះទេ ប៉ុន្តែលើមុខងារ និងកិច្ចការផ្សេងទៀតផងដែរដែលពួកគាត់កំពុងអនុវត្ត។ មន្ត្រីត្រូវការទាំងផ្នែកបច្ចេកទេស និងចំណេះដឹងអន្តរបុគ្គល។ ដូចគ្នាផងដែរ អ្នកតំណាងជាប់ឆ្នោតត្រូវយល់ដឹងពីអ្វីទៅជាអត្ថន័យនៃការប្រគល់មុខងារអប់រំដល់ក្រុង ស្រុក សម្រាប់តួនាទី និងការទទួលខុសត្រូវនៃក្រុមប្រឹក្សាមូលដ្ឋាន។

ទោះបីថានៅមានកម្រិត ក៏បទពិសោធន៍ដែលទទួលបានពីខេត្តបាត់ដំបងអំពីការអនុវត្តមុខងារវិស័យអប់រំ មិនបានបង្ហាញពីហានីភ័យ ឬឧបសគ្គធ្ងន់ធ្ងរណាមួយសម្រាប់ការអនុវត្តវិស័យនេះនោះទេ។ ទោះជាយ៉ាងក៏ដោយ គឺបានបង្ហាញពីទិដ្ឋភាពសំខាន់ៗអំពីរបៀបដែលស្ថាប័នថ្នាក់ជាតិ និងថ្នាក់ខេត្តត្រូវគ្រប់គ្រងដំណើរការផ្ទេរ និងផ្តល់ការគាំទ្រ និងចង្អុលបង្ហាញអំឡុងពេលដំណាក់កាលអន្តរកាល។

# ១. ការណែនាំ

## ១.១ គោលបំណង និងសាវតា

របាយការណ៍នេះសង្ខេបបានជាមេរៀន និងបទពិសោធន៍អនុវត្តពីការប្រគល់មុខងារអប់រំ ដែលត្រូវបានផ្ទេរទៅដល់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។ សំណួរសំខាន់ៗដែលត្រូវបានស្វែងយល់គឺជាអ្វីដែលបានអនុវត្តយ៉ាងល្អប្រសើ ហើយអ្វីដែលនៅមិនទាន់ល្អ និងចាំបាច់ត្រូវកែលម្អទាំងនៅក្នុងខេត្តបាត់ដំបង និងផែនការត្រូវពង្រីកទៅខេត្តដទៃទៀត។

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញអនុក្រឹត្យលេខ ១៨២ និង១៨៤ អនក្រ.បក ស្តីពីមុខងារ និងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង( ១៨២ ) ហើយមុខងារ និងរចនាសម្ព័ន្ធនៃរដ្ឋបាលស្រុក ( ១៨៤ )ដាច់ដោយឡែកពីគ្នា។

អនុក្រឹត្យទាំងនេះមានគោលបំណង លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍មូលដ្ឋាន នៅថ្នាក់ក្រុង ស្រុក ជាមួយនឹងគោលដៅ ដើម្បីកំណត់នូវមុខងាររចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវ ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលនីមួយៗ។ អនុក្រឹត្យទាំងពីរក៏បានបង្ហាញផងដែរនូវវឌ្ឍនភាពសំខាន់ៗនៃកំណែទម្រង់ក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដោយការផ្ទេរនូវមុខងារជាច្រើន រាប់បញ្ចូលទាំងវិស័យអប់រំពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ទៅដល់រដ្ឋបាលក្រុង ស្រុក។ ការផ្ទេរមុខងារត្រូវបានធ្វើឡើងតាមពីររបៀប គឺការប្រគល់ និងប្រតិភូមកម្ម។ តាមបែបនៃការប្រគល់ រដ្ឋបាលថ្នាក់ក្រោមជាតិមានអំណាចពេញលេញដើម្បីគ្រប់គ្រង ហើយអនុវត្តមុខងារនានាដែលពួកគាត់ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចេញក្នុងឆ្នាំ២០០៨។ តាមបែបនៃការធ្វើប្រតិភូកម្ម ទោះជាយ៉ាងក៏ដោយ រដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចអនុវត្តមុខងារដែលបានកំណត់ដោយអង្គភាពធ្វើប្រតិភូកម្ម ហើយពួកគាត់ត្រូវទទួលខុសត្រូវជាចម្បង ចំពោះក្រសួង ឬស្ថាប័នទាំងនោះ។ មុខងារវិស័យអប់រំត្រូវបានផ្ទេរតាមបែបប្រតិភូកកម្មទៅឲ្យរាជធានី និងខេត្តទាំងអស់ទូទាំងប្រទេសកម្ពុជា លើកលែងតែខេត្តបាត់ដំបងដែលមុខងារអប់រំចំនួនបី មានៈ អប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្ទេរតាមបែបនៃការប្រគល់។

ខេត្តបាត់ដំបងត្រូវបានចាត់ទុកជាកន្លែងសាកល្បងសម្រាប់អនុវត្តគោលនយោបាយឆ្នាំ២០១៦ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការលើវិស័យអប់រំបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ គោលបំណងនៃគោលនយោបាយគឺដើម្បីពង្រឹងស្វ័យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់

ក្រោមជាតិ (ជាពិសេសនៅថ្នាក់រដ្ឋបាលក្រោមជាតិ) ហើយស្ថាប័នអប់រំសាធារណៈដែលពួកគេអាចផ្តល់គុណភាពសេវាអប់រំប្រកបដោយតម្លាភាព និងសមភាពចំពោះប្រជាពលរដ្ឋ។ ការផ្ទេរមុខងារ និងធនធានក្នុងវិស័យអប់រំ យុវជន និងកីឡា ត្រូវបានធ្វើឡើងជាបណ្តើរៗដោយមានការប្រុងប្រយ័ត្ន។ មានការរំពឹងទុកថា ពទពិសោធន៍ និងមេរៀនដែលទទួលបានពីដំណើរការអនុវត្តពីខេត្តបាត់ដំបងនឹងត្រូវផ្តល់ការយល់ដឹងដ៏មានតម្លៃសម្រាប់ការប្រគល់មុខងារអប់រំបានពេញលេញនាពេលអនាគត ដល់ក្រុង ស្រុក និងបណ្តាខេត្តដ៏ទៃទៀតក្នុងប្រទេសកម្ពុជា។

## ១.២ វិធីសាស្ត្រ និងដែនកំណត់

ការសិក្សាបានធ្វើការសម្ភាសន៍ពាក់កណ្តាលផ្លូវការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ (សូមមើលឧបសម្ព័ន្ធទី១ និងបញ្ជីអ្នកផ្តល់ព័ត៌មានសំខាន់ៗ) និងបានពិនិត្យឯកសារច្បាប់ និងឯកសារផ្សេងទៀតទាក់ទងដំណើរការអនុវត្តក្នុងខេត្តបាត់ដំបង។ ការសង្កេតលើការអនុវត្តគោលនយោបាយនៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងក៏ត្រូវបានធ្វើឡើងក្នុងខែមិថុនា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២១។ ពីមួយពេលទៅមួយពេលអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានស្នើសុំឲ្យចែករំលែកការឆ្លុះបញ្ចាំងរបស់ពួកគេលើដំណើរការអនុវត្ត។ សិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិមួយត្រូវបានធ្វើឡើងតាមអ៊ិនធឺណិតនៅថ្ងៃទី២៩-៣០ ខែកក្កដា ឆ្នាំ២០២១។ សិក្ខាសាលាឆ្លុះបញ្ចាំងមួយទៀតក៏ត្រូវបានធ្វើឡើងនៅថ្ងៃទី២៤ ខែមិនា ឆ្នាំ២០២២ (សូមមើលព័ត៌មានលំអិតក្នុងឧបសម្ព័ន្ធ២)។

គួរកត់សម្គាល់ថា ការរកឃើញនិងការសង្កេតលើរបាយការណ៍នេះក៏មាននូវដែនកំណត់ខ្លះៗ។ តាំងពីអនុក្រឹត្យ១៨២-១៨៤ត្រូវបានអនុម័តនៅចុងឆ្នាំ២០១៩ ការរាតត្បាតនៃជម្ងឺកូវីដ-១៩បានជះឥទ្ធិពលប៉ះពាល់យ៉ាងខ្លាំងដល់ការខិតខំប្រឹងប្រែងរបស់រដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡារបស់ក្រុង ស្រុកក្នុងខេត្តបាត់ដំបង។ សាលារៀនស្ទើរតែទាំងអស់ត្រូវបានបិទទ្វារ ហើយត្រូវបានដាក់ទៅជាមណ្ឌលចត្តាឡីស័កនិងមណ្ឌលព្យាបាលកូវីដ-១៩។ តែទោះជាយ៉ាងណា ការយកចិត្តទុកដាក់ជាចម្បងរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគឺបានផ្តោតបន្ថែមទៀតទៅលើយន្តការឆ្លើយតបដែលមានប្រសិទ្ធភាពទៅនឹងករណីមានអាសន្នណាមួយជាជាងមុខងារអប់រំដែលបានប្រគល់ឬផ្ទេរ។ ម៉្យាងវិញទៀត ការអនុវត្តមុខងារអប់រំដែលបានផ្ទេរតាំងពីដើមឆ្នាំ២០២០បានកើតឡើងក្នុងបរិបទយ៉ាងដាក់លាក់ ហើយប្រហែលជាមិនស្ថិតនៅក្នុងកម្រិតនៃការតាំងចិត្តដែលជាទូទៅអាចរំពឹងទុកនោះទេ។

របាយការណ៍នេះផ្តោតសំខាន់ទៅលើបទពិសោធន៍ ការសង្កេត និងការយល់ដឹងដែលមន្ត្រីវិស័យអប់រំទទួលបាននៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក។ ការទទួលខុសត្រូវលើមុខងារអប់រំទាំងបីដែលត្រូវបានប្រគល់ទៅរដ្ឋបាលក្រុង ស្រុក ក៏បានប្រឈមទៅនឹងកង្វះខាតផ្នែកនីតិវិធីរដ្ឋបាល និងផ្នែកហិរញ្ញវត្ថុផ្សេងៗ ដែលជារឿយៗមិនទាន់ត្រូវបានឆ្លើយតបភ្លាមៗបាន។ របាយការណ៍នេះបានលើកយកមកបង្ហាញពីបញ្ហាប្រឈមនានា និងរបៀបដែលពួកវាអាចត្រូវបានដោះស្រាយ (ឬពេលខ្លះត្រូវបានទុកចោលដោយមិនបានដោះស្រាយ)។ របាយការណ៍នេះមិនមែនជាការវាយតម្លៃផលប៉ះពាល់ ឬលទ្ធផលនៃដំណើរការប្រគល់មុខងារអប់រំឡើយ។ ពោលគឺវាមិនបានផ្តល់ចម្លើយ ថាតើបរិមាណ និងគុណភាពនៃសេវាអប់រំត្រូវបានកែលម្អ ឬធ្លាក់ចុះបន្ទាប់ពីការប្រគល់មុខងារទាំងនោះទៅដល់រដ្ឋបាលក្រុង ស្រុកនោះទេ ហើយវាក៏មិនមែនជាការប្រៀបធៀបលទ្ធផលនៃការផ្ទេរមុខងារតាមរបៀបដែលត្រូវបានយកមកអនុវត្តនោះឡើយ។

## ១.៣ គ្រោងនៃរបាយការណ៍

ជាបន្តបន្ទាប់ របាយការណ៍នេះត្រូវបានរៀបចំឡើងដូចខាងក្រោម៖

- ផ្នែកទី២ ផ្តល់នូវទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការផ្ទេរមុខងារអប់រំ
- ផ្នែកទី៣ វាយតម្លៃការរៀបចំរបស់ស្ថាប័ន និងពិពណ៌នាអំពីបញ្ហាប្រឈមដែលបានរកឃើញក្នុងអំឡុងពេលអនុវត្តការផ្ទេរមុខងារអប់រំនៅចន្លោះដើមឆ្នាំ២០២០ ដល់ចុងឆ្នាំ២០២១
- ផ្នែកទី៤ បង្ហាញពីមេរៀនដែលបានមកពីការសង្កេត និងការវាយតម្លៃ
- ផ្នែកចុងក្រោយ (ផ្នែកទី៥) ផ្តល់នូវអនុសាសន៍មួយចំនួនសម្រាប់ការពិចារណា។

## ២. ក្របខណ្ឌច្បាប់

គោលនយោបាយអប់រំ និងអនុក្រឹត្យមួយចំនួនត្រូវបានដាក់សម្រាប់ធ្វើវិមជ្ឈការក្នុងវិស័យអប់រំនៅកម្ពុជា។ សំខាន់ជាបំផុតគឺអនុក្រឹត្យលេខ ១៨២-១៨៤ ចេញផ្សាយនាខែធ្នូ ឆ្នាំ២០១៩។ លើសពីនេះ ក៏មានការអនុវត្តបទប្បញ្ញត្តិរដ្ឋបាលជាច្រើនដែលត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងបទពិសោធន៍អនុវត្តជាក់ស្តែងមួយចំនួន។ ផ្នែកនេះផ្តល់នូវទិដ្ឋភាពទូទៅនៃគោលនយោបាយ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីបរិបទច្បាប់ និងគោលនយោបាយនៃវិមជ្ឈការក្នុងវិស័យអប់រំ។

### ២.១ គោលការណ៍ណែនាំគោលនយោបាយសំខាន់ៗ៖ គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយរបស់ខ្លួនស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ដើម្បីពង្រឹងស្វ័យភាព និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នអប់រំសាធារណៈ។ គោលនយោបាយត្រូវបានបង្កើតឡើងដើម្បីសម្រេចគោលដៅចំនួន៤។ ទី១ គឺដើម្បីបង្កើតក្របខណ្ឌច្បាប់ចាំបាច់ និងយន្តការគ្រប់គ្រងវិស័យអប់រំ ស្របជាមួយនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិនៃរដ្ឋាភិបាលនៃកម្ពុជា។ ទី២ គោលនយោបាយ មានគោលបំណងផ្ទេរមុខងារអប់រំ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នអប់រំ។ វាក៏ដើម្បីពង្រឹងស្ថាប័ន និងរដ្ឋបាលក្នុងការគ្រប់គ្រង និងផ្តល់សេវាអប់រំផងដែរ។ ជាចុងក្រោយ គឺការលើកកម្ពស់សមភាពសង្គម បរិយាប័ន្ន ការចូលរួម និងការទទួលខុសត្រូវពីបុគ្គលិកអប់រំ មាតាបិតា និងប្រជាពលរដ្ឋ ដើម្បីផ្តល់ និងទទួលយកសេវាអប់រំប្រកបដោយគុណភាព។

នៅក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន (ឆ្នាំ២០១៩-២០២៣) ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់ដោយសង្ខេបពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយលើកឡើងពីការទទួលខុសត្រូវសំខាន់ៗរបស់ស្ថាប័នមួយចំនួនដូចខាងក្រោម ៖

- ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកពិនិត្យមុខងារ និងធនធានដែលត្រូវផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ វាជាកាតព្វកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគោលការណ៍ណែនាំផ្លូវច្បាប់ និងជ្រើសរើស បណ្តុះបណ្តាល និងអភិវឌ្ឍគ្រូបង្រៀនថ្មី។
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គឺជាអន្តរការីរវាងក្រសួងអប់រំ យុវជន និងកីឡា ការិយាល័យអប់រំយុវជន និងកីឡាក្រុង ស្រុក និងគ្រឹះស្ថានអប់រំ។ វាក៏ដើម្បីជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ទៅតាមតួនាទីដែលបានកំណត់ (ត្រូវពិនិត្យដោយក្រសួងអប់រំ យុវជន និងកីឡា ស្រប

តាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ) ក្នុងការសម្របសម្រួល និងគាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងគ្រឹះស្ថានអប់រំក្នុងការអនុវត្តគោលនយោបាយអប់រំ។ លើសពីនេះ វាក៏ជួយដល់រដ្ឋបាលរាជធានី ក្រុង ខេត្ត ក្នុងនាមសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសផងដែរ។

- ការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ក្រុង គឺជាអន្តរការីរវាងក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានអប់រំនានា។ វាគឺជួយសម្របសម្រួល គាំទ្រ និងរាយការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា ទៅតាមតួនាទីជាអង្គភាពគាំទ្រផ្នែកខាងក្រោយ ក្នុងការផ្តល់មុខងារអប់រំ។ វាគឺដើម្បីសង្កេតមើលការសម្រេចចិត្តណាមួយ ដែលធ្វើឡើងដោយរដ្ឋាភិបាល នៅក្នុងកំណែទម្រង់មុខងាររដ្ឋឯកភាព។
- ស្ថាប័នអប់រំកំពុងដើរតួជាអង្គភាពជួរមុខក្នុងការផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋ។ រហូតមកដល់ពេលនេះ គ្រឹះស្ថានអប់រំ មានស្វ័យភាពផ្ទាល់ខ្លួនក្នុងការរៀបចំផែនការ និងការគ្រប់គ្រងធនធានរបស់ពួកគេ។ ក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងផ្ទេរថវិកាដោយផ្ទាល់ទៅគណនីគ្រឹះស្ថានអប់រំតាំងពីឆ្នាំ ២០០០។

## ២.២ ឧបករណ៍ច្បាប់សំខាន់ៗ៖ អនុក្រឹត្យលេខ ១៨២-១៨៤ អនក្រ.បក

អនុក្រឹត្យលេខ ១៨២-១៨៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី "មុខងារ និងរចនាសម្ព័ន្ធ" របស់រដ្ឋបាលក្រុង ស្រុក ធ្វើឱ្យកាន់តែស៊ីជម្រៅនូវគោលនយោបាយកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយផ្ទេរការទទួលខុសត្រូវ និងធនធានសម្រាប់មុខងារវិស័យជាច្រើនទៅកាន់រដ្ឋបាលក្រុង ស្រុកនៅកម្ពុជា។ អនុក្រឹត្យនេះក៏រួមបញ្ចូលការិយាល័យវិស័យជាច្រើនចូលទៅក្នុងការគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់រដ្ឋបាលក្រុង ស្រុក ហើយដូច្នេះបង្កើតរដ្ឋបាលឯកភាពមួយនៅកម្រិតក្រុង ស្រុក។ សម្រាប់ខេត្តបាត់ដំបង ការរៀបចំពិសេសត្រូវបានធ្វើឡើងសម្រាប់ការផ្ទេរមុខងារអប់រំតាមមុខងារដែលបានប្រគល់ (ជំពូកទី៧ និងឧបសម្ព័ន្ធទី៤) បើធៀបនឹងខេត្តផ្សេងទៀតដែលមុខងារនេះត្រូវបានផ្ទេរជាមុខងារប្រតិភូកម្ម។

មាត្រា ៥៩ ក្នុងជំពូកនេះ ចែងថា "ការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងបឋមសិក្សា និងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធត្រូវបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុក នៃខេត្តបាត់ដំបង ខណៈដែល "ការគ្រប់គ្រងការអប់រំមធ្យមសិក្សា ការអភិវឌ្ឍន៍យុវជន និងការអប់រំកាយ និងកីឡាត្រូវបានប្រតិភូកម្ម"។ មុខងាររង និងសកម្មភាពនៃមុខងារដែលត្រូវបានប្រគល់ និងប្រតិភូកម្ម ក៏ត្រូវបានបញ្ជាក់នៅក្នុងអនុក្រឹត្យនេះផងដែរ។ មាត្រា ៦០ ចែងថា គ្រឹះស្ថានមត្តេយ្យសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍របស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្នាក់ក្រុង និងស្រុក ត្រូវដាក់បញ្ចូល

ទៅក្នុងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុករៀងៗខ្លួន។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវបានអនុញ្ញាតឱ្យរៀបចំផែនការ ដឹកនាំ សម្របសម្រួល និងវាយតម្លៃដំណើរការអនុវត្ត ដើម្បីអាចផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រៀបចំរបៀបរបបការងារនៅពេលអនាគត។

## ២.៣ បទប្បញ្ញត្តិ/សេចក្តីណែនាំរដ្ឋបាល

នៅក្នុងដំណើរការនៃការផ្ទេរមុខងារអប់រំទៅរដ្ឋបាលក្រុង ស្រុក បទប្បញ្ញត្តិ និងគោលការណ៍ណែនាំរដ្ឋបាលមួយចំនួនចាំបាច់ត្រូវបង្កើតដើម្បីដោះស្រាយបញ្ហាជាក់ស្តែង។ ទាំងនេះទាក់ទងនឹងស្ថានភាពជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង ដែលកំពុងគ្រប់គ្រងមុខងារអប់រំដែលបានផ្ទេរក្នុងទម្រង់ប្រគល់មុខងារ ខណៈពេលស្ថាប័នផ្សេងទៀតបានដោះស្រាយបញ្ហាទូទៅចំពោះរដ្ឋបាលក្រុង ស្រុកទាំងអស់ដែលគ្រប់គ្រងមុខងារអប់រំក្នុងរបៀបប្រតិភូកម្មមុខងារ។ បទប្បញ្ញត្តិទាំងនេះរួមមានដូចខាងក្រោម៖

### ២.៣.១ ក្រសួងមហាផ្ទៃ៖ សេចក្តីណែនាំលេខ ០៥៥ ស.ណ.ន

ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០៥៥ សណន ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី "ការធានាឱ្យបាននូវនិរន្តរភាពក្នុងការងាររដ្ឋបាល និងការផ្តល់សេវាក្នុងដំណើរការគ្រប់គ្រងរចនាសម្ព័ន្ធក្រុង ស្រុក និងខណ្ឌថ្មី" ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់នៅកម្ពុជា។ ការណែនាំនេះមានគោលបំណងធានាឱ្យមាននូវនិរន្តរភាពនៃការងាររដ្ឋបាល និងការផ្តល់សេវា ខណៈពេលដែលការគាំទ្រដល់ឧបករណ៍ច្បាប់ដែលពាក់ព័ន្ធនឹងនីតិវិធីរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃការរៀបចំថ្មីនេះនៅតែមិនទាន់មាន។ សេចក្តីណែនាំនេះស្នើដល់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ មន្ទីរវិស័យថ្នាក់ខេត្ត ការិយាល័យវិស័យ និងអង្គភាពពាក់ព័ន្ធនៃក្រសួង និងស្ថាប័ននៅថ្នាក់ក្រុង/ស្រុក/ខណ្ឌ ដើម្បីសហការក្នុងការកត់ត្រាការផ្ទេរ និងការទទួលតួនាទី និងការទទួលខុសត្រូវ រួមទាំងកិច្ចការ ឯកសារ ទ្រព្យសម្បត្តិ ទ្រព្យសកម្ម ចំណូល ចំណាយ បំណុល និងថវិកា។

ផ្នែកទី១ នៃសេចក្តីណែនាំនេះពិពណ៌នាអំពីរបៀបដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌគួរតែគ្រប់គ្រងនិរន្តរភាពនៃការងាររដ្ឋបាល និងការផ្តល់សេវា។ វាត្រូវបានទាមទារថា ប្រសិនបើចាំបាច់ ការិយាល័យបច្ចេកទេសដែលទទួលខុសត្រូវលើសេវារដ្ឋបាល សេវាសាធារណៈ និងកិច្ចការហិរញ្ញវត្ថុអាចបន្តធ្វើអ្វីដែលពួកគេធ្លាប់ធ្វើរហូតដល់មានការជូនដំណឹងបន្ថែម។ ផ្នែកទី២ លើកទឹកចិត្តរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ឱ្យរាយបញ្ជីកិច្ចការទាំងអស់ដែលពួកគេកំពុងធ្វើ សម្រាប់គោលបំណងនៃការផ្ទេរ។ ផ្នែកទី៣

កាតព្វកិច្ចដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិទាំងអស់ដែលពួកគេមាន។ ផ្នែកទី៤ ណែនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យរៀបចំរបាយការណ៍ស្តីពីកិច្ចសន្យា កាតព្វកិច្ច និងហិរញ្ញវត្ថុ។ ផ្នែកទី៥ ស្នើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌចងក្រង និងរាយការណ៍បញ្ជីឯកសារផ្លូវច្បាប់ណាមួយដែលពួកគេបានដាក់ចេញមុនពេលផ្ទេរមុខងារ។ ជាចុងក្រោយ ផ្នែកទី៦ ពិពណ៌នាអំពីយន្តការអនុវត្ត ដែលគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវអនុវត្ត ដើម្បីរៀបចំសម្រាប់ការផ្ទេរភារកិច្ចបែបនេះ។

### ២.៣.២ ក្រសួងមហាផ្ទៃ៖ សេចក្តីជូនដំណឹង ១៦២២ ស.ជ.ណ

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃ បានចេញសេចក្តីជូនដំណឹងមួយទៀតចុះលេខ ១៦២២ ស.ជ.ណ ស្តីពី "ការពង្រឹងការគ្រប់គ្រងរដ្ឋបាលនៅក្រុង ស្រុក និងខណ្ឌ"។ សេចក្តីជូនដំណឹងនេះបានកត់សម្គាល់ឃើញថា ការិយាល័យនីមួយៗដែលត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅតែធ្វើទំនាក់ទំនងទៅមន្ទីររបស់ខ្លួននៅថ្នាក់ខេត្តដដែល ដូចមុនពេលផ្ទេរមុខងារ ដែលមិនស្របតាមអនុក្រឹត្យលេខ ១៨២-១៨៤។ សេចក្តីជូនដំណឹងណែនាំថា សំបុត្រផ្លូវការទាំងអស់ត្រូវតែឆ្លងកាត់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយត្រូវតែមានហត្ថលេខា និងត្រារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ នាយកដ្ឋាន/មន្ទីរនៅថ្នាក់ជាតិ/ខេត្តក៏ត្រូវបានស្នើសុំឱ្យធ្វើទំនាក់ទំនងតាមរយៈរដ្ឋបាលក្រុង ស្រុក ខណ្ឌផងដែរ ប្រសិនបើពួកគេចង់ទាក់ទងការិយាល័យវិស័យនៅកម្រិតរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការិយាល័យនីមួយៗដែលបានធ្វើសមាហរណកម្មទៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌមិនអាចចុះហត្ថលេខា ឬបោះត្រាដូចដែលពួកគេធ្លាប់ធ្វើតទៅទៀតទេ។ វា ឥឡូវនេះ ជាការសម្រេចរបស់រដ្ឋបាលស្រុក/ក្រុង ថាតើកន្លែងណាជាកន្លែងដែលត្រូវចុះហត្ថលេខា បោះត្រា និងធ្វើការទំនាក់ទំនងទៅកាន់អ្នកទទួលនៅខាងក្រៅ។

ទោះជាយ៉ាងនេះក្តី សេចក្តីជូនដំណឹងនេះ មិនមានផ្នែកដាច់ដោយឡែកដែលមានគោលបំណងជាពិសេសនៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង ដែលមុខងារអប់រំត្រូវបានផ្ទេរទាំងនៅក្នុងរបៀបប្រគល់ និងប្រតិភូកម្ម។ វាត្រូវបានកត់សម្គាល់ថាមុនពេលផ្ទេរមុខងារ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក មានត្រាផ្ទាល់ខ្លួនហើយពួកគេអាចប្រើវាដើម្បីទំនាក់ទំនងជាមួយដៃគូខាងក្រៅ និងគ្រឹះស្ថានសិក្សារបស់ពួកគេ។ បន្ទាប់ពីការផ្ទេរ ជាអកុសល មិនទាន់មានការណែនាំច្បាស់លាស់នៅឡើយទេ អំពីរបៀបប្រើប្រាស់ត្រាការិយាល័យនេះ។ នេះបណ្តាលឱ្យមានការភ័ន្តច្រឡំ ដែលនៅផ្នែកខាងក្រោយៗនៃឯកសារនេះនឹងមានបន្លិចឡើង។

### ២.៣.៣ ប្រកាសអន្តរក្រសួងលេខ ៥២១ សហវ.បក

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានចេញប្រកាសលេខ ៥២១ សហវ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពី "លក្ខខណ្ឌហិរញ្ញវត្ថុ និង

បច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរថវិកាមានភ្ជាប់លក្ខខណ្ឌដល់រដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង ដើម្បីអនុវត្តមុខងារអប់រំនៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ គោលបំណងនៃប្រកាសនេះគឺដើម្បីផ្ទេរហិរញ្ញប្បទានមានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង ដើម្បីឱ្យពួកគេអាចប្រើប្រាស់ និងគ្រប់គ្រងមុខងារអប់រំដែលបានប្រគល់ឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល គណនេយ្យភាព និងតម្លាភាពចាប់ពីឆ្នាំ២០២១តទៅ។

ប្រកាសនេះពិពណ៌នាអំពីតួនាទី ការទទួលខុសត្រូវ និងគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកនឹងដើរតួជាជំនួយការ ហើយត្រូវតែទទួលខុសត្រូវចំពោះរដ្ឋបាលក្រុង ស្រុក។ ដោយមានជំនួយបច្ចេកទេសពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយនិងការណែនាំពីរដ្ឋបាលក្រុង ស្រុក ការិយាល័យអប់រំយុជន និងកីឡាក្រុង ស្រុកនឹងរៀបចំផែនការថវិកា ហើយប្រើប្រាស់វាទៅតាមគោលការណ៍ និងសេចក្តីណែនាំហិរញ្ញវត្ថុដែលមានស្រាប់។ ផែនការថវិកាសម្រាប់ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវភ្ជាប់ជាឧបសម្ព័ន្ធជាមួយថវិការដ្ឋបាលក្រុង ស្រុក។ រដ្ឋបាលក្រុង ស្រុកនឹងស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត សម្រាប់ការជ្រើសរើសគ្រូបង្រៀន និងការកសាងសមត្ថភាពគ្រូបង្រៀន ប្រសិនបើចាំបាច់។ ប្រសិនបើមានតម្រូវការកាត់បន្ថយ ឬបង្កើនខ្ទង់ថវិកា ដើម្បីឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុក ដើម្បីកែតម្រូវទៅតាមនោះ។ វាត្រូវបានកត់សម្គាល់ថាមុនពេលផ្ទេរមុខងារអប់រំមន្ទីរអប់រំ យុវជន និងកីឡាខេត្តមានទំនួលខុសត្រូវទាំងស្រុងក្នុងការរៀបចំផែនការ និងអនុវត្តថវិកាដោយមានជំនួយពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក។ ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីការផ្ទេរមុខងារវិស័យអប់រំនេះមក ការទទួលខុសត្រូវនេះជាបន្ទុករបស់រដ្ឋបាលក្រុង ស្រុក។

### ២.៣.៤ ក្រសួងមហាផ្ទៃ៖ សេចក្តីសម្រេចលេខ ២៩៩៤ សសរ

ក្រសួងមហាផ្ទៃបានចេញសេចក្តីសម្រេចមួយទៀត លេខ ២៩៩៤ សសរ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពី "ការបង្កើតក្រុមការងាររៀបចំឯកសារបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងមុខងារអប់រំនៅរដ្ឋបាលក្រុង ស្រុក និងខណ្ឌ"។ នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) ជាប្រធានក្រុមការងារ រួមជាមួយនឹងសមាជិកជិតសាមសិបនាក់មកពីក្រសួងអប់រំ យុវជន និងកីឡា គ.ជ.អ.ប និងក្រសួងមហាផ្ទៃ។ កាតព្វកិច្ចចម្បងរបស់ក្រុមនេះគឺសរសេរសៀវភៅណែនាំស្តីពីការគ្រប់គ្រងមុខងារវិស័យអប់រំ និងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ក្រុមនេះត្រូវបានប្រគល់ភារកិច្ចឱ្យដើម្បី៖

- រៀបចំផែនការសកម្មភាព ដើម្បី ធ្វើការបណ្តុះបណ្តាលបច្ចេកទេស ស្តីពី មុខងារអប់រំសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់

- បង្កើតសៀវភៅណែនាំស្តីពីការគ្រប់គ្រងវិស័យអប់រំនៅកម្រិតក្រុង ស្រុក ខណ្ឌ
- បង្កើតសៀវភៅបណ្តុះបណ្តាលស្តីពីមុខងារអប់រំនៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ធ្វើការបណ្តុះបណ្តាលលើមុខងារអប់រំ
- អនុវត្តការងារចាំបាច់ និងពាក់ព័ន្ធផ្សេងទៀត។

ភារកិច្ចរបស់ក្រុមនេះ មិនឆ្លុះបញ្ចាំងពីបញ្ហាប្រឈមជាក់លាក់របស់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង ដែលគ្រប់គ្រងមុខងារអប់រំក្នុងទម្រង់ដែលបានប្រគល់នោះទេ។ ក្រុមនេះបានជួបគ្នាជាច្រើនលើកដើម្បីពិភាក្សាអំពីមុខងារអប់រំបច្ចេកទេស។ នៅពេលនេះ សៀវភៅណែនាំ និងសៀវភៅបណ្តុះបណ្តាលមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ។

### ២.៣.៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ សារាចរណែនាំលេខ ០០១ សហវ

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ ០០១សហវ ស្តីពី "ការអនុវត្តនីតិវិធីថវិកា គណនេយ្យ និងចលនាឥណទាននៃការផ្ទេរហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលក្រុង ស្រុកចំនួន១៤ នៅខេត្តបាត់ដំបង ដើម្បីអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ មានផ្នែកសំខាន់ពីរនៃសារាចរណែនាំនេះ។ ទីមួយបង្ហាញពីនីតិវិធីអនុវត្តនៃការរៀបចំថវិកា និងការរៀបចំគណនេយ្យសម្រាប់ការអនុវត្តមុខងារដែលបានប្រគល់ ខណៈដែលមួយចំណុចចុងក្រោយគឺបង្ហាញអំពីចលនាឥណទាន ដោយណែនាំផ្នែកណាមួយនៃគណនីដែលរដ្ឋបាលក្រុង ស្រុក អាចផ្លាស់ប្តូរ និងប្រើប្រាស់ថវិកានេះ។

សារាចរណែនាំនេះ បានបង្ហាញជាក់លាក់ដល់រដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកក្នុងខេត្តបាត់ដំបង ដោយបានផ្តល់នីតិវិធីលំអិត ដែលចែងមិនច្បាស់លាស់ក្នុងសេចក្តីប្រកាសរួម លេខ ៥២១ សហវ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពី លក្ខខណ្ឌហិរញ្ញវត្ថុ និងបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដល់រដ្ឋបាលក្រុង ស្រុកទាំង ១៤ នៅក្នុងខេត្តបាត់ដំបង ដើម្បីអនុវត្តមុខងារនៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ (សូមមើលចំណុច ២.២.៣ ខាងលើ)។

## ២.៤ ការសង្កេត និងការវាយតម្លៃ

ខណៈពេលដែលអនុក្រឹត្យលេខ ១៨២-១៨៤ ចេញនៅឆ្នាំ២០១៩ ផ្តល់មូលដ្ឋានសម្រាប់ការផ្ទេរមុខងារវិស័យអប់រំទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (ទាំងនៅក្នុងរបៀបប្រគល់ និងប្រតិភូកម្ម) អនុក្រឹត្យតែមួយមិនគ្រប់គ្រាន់ដើម្បីណែនាំ និងដឹកនាំដំណើរការអនុវត្តនៅថ្នាក់ក្រោមជាតិនោះទេ។ សេចក្តីណែនាំ

និងគោលការណ៍ណែនាំច្រើនទៀតបានដាក់ចេញឡើង ដើម្បីបញ្ជាក់អំពីបញ្ហា និងឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែងមួយចំនួនក្នុងការអនុវត្តនៃការផ្ទេរមុខងារ។ វាទំនងជាថាសេចក្តីណែនាំ និងគោលការណ៍ណែនាំបែបនេះ នឹងត្រូវដាក់ចេញដោយផ្អែកលើមតិកែលម្អពីដំណើរការអនុវត្តនៅក្រុង ស្រុក។

# ៣. ស្ថាប័នគាំទ្រ

ការរៀបចំស្ថាប័នមានសារៈសំខាន់ណាស់ក្នុងការគាំទ្រជាយុទ្ធសាស្ត្រ សម្របសម្រួល និងអនុវត្តការផ្ទេរមុខងារវិស័យអប់រំ។ ខណៈពេលដែលមានការកត់សម្គាល់ ពីការរៀបចំស្ថាប័នដ៏ស្មុគស្មាញ នៅក្នុងប្រទេសកម្ពុជា ផ្នែកនេះបង្ហាញពីតួនាទីសំខាន់របស់ស្ថាប័នមួយចំនួន ដែលអាចសម្របសម្រួល និងពង្រឹងដំណើរការអនុវត្តនៅកម្រិតរដ្ឋបាលចំនួនពីរ៖ រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង/ស្រុក។

## ៣.១ មន្ទីរអប់រំយុវជន និងកីឡាខេត្ត

មន្ទីរអប់រំ យុវជន និងកីឡាខេត្តទាំងអស់ដើរតួជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡា និងត្រូវកំណត់ឱ្យស្រាវជ្រាវរក អនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ និងគោលការណ៍ណែនាំវិស័យពាក់ព័ន្ធដែលបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ពួកគេត្រូវបានគេរំពឹងថានឹងធ្វើក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងគ្រប់គ្រងបុគ្គលិក ទ្រព្យសកម្ម និងស្ថាប័នអប់រំនៅក្នុងខេត្តរបស់ពួកគេ។ ពួកគេក៏ត្រូវសហការ និងសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងទឹកដីរបស់ពួកគេរៀងៗខ្លួន។ ដើម្បីមានគណនេយ្យភាពចំពោះក្រសួងអប់រំ យុវជន និងកីឡា និងសង្កេតមើលគោលនយោបាយបច្ចុប្បន្នស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង បានបង្កើតឯកសារសំខាន់ៗជាច្រើន ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវដែលបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ ទាំងនេះរួមមានផែនការយុទ្ធសាស្ត្រអប់រំខេត្ត ២០១៩-២០២៣ ផែនការថវិកាបីឆ្នាំរំកិល ២០២០-២០២៣ ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ។ ការពិនិត្យឡើងវិញនូវឯកសារដែលមានស្រាប់ និងការជួបជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗពីមន្ទីរអប់រំ យុវជន និងកីឡា ការសិក្សាកត់សម្គាល់នូវបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ៖

1. ទី១ មន្ទីរអប់រំ យុវជន និងកីឡា មិនទាន់ដំណើរការនៅឡើយទេ យោងទៅតាមគោលការណ៍ចុងក្រោយស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ។ ជាឧទាហរណ៍ តួនាទី និងទំនួលខុសត្រូវរបស់ខ្លួនដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលចេញក្នុងឆ្នាំ ១៩៩៩ គឺមិនស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ ២០១៦ ស្តីពីការអប់រំ និងអនុក្រឹត្យលេខ ១៨២-១៨៤ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំនោះទេ។ គេសង្កេត

ឃើញថា ក្រសួងអប់រំ យុវជន និងកីឡា នៅតែស្ថិតក្នុងដំណើរការពិនិត្យ និងចេញប្រកាសថ្មី ដើម្បីបង្ហាញពីតួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់មន្ទីរអប់រំ យុវជន និងកីឡា ឱ្យស្រប តាមអនុក្រឹត្យលេខ ១៨២ និង១៨៤ សម្រាប់គាំទ្រដល់ការអនុវត្តការផ្ទេរមុខងារអប់រំទៅឱ្យរដ្ឋ បាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។

2. ទី២ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀន និងនាយកសាលា ប៉ុន្តែមិនមែនមន្ត្រីវិស័យ ដែលពួកគាត់កំពុងគ្រប់គ្រង និងគាំទ្រវិស័យអប់រំនៅមន្ទីរអប់រំ យុវជន និងកីឡានោះទេ។ មិនទាន់មានផែនការ ឬថវិកាដែលបានបែងចែកនៅឡើយទេ ដើម្បីកសាងសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងនៃការិយាល័យគាំទ្រ ដូចជាការិយាល័យរដ្ឋបាល ផែនការ បុគ្គលិក និងការបណ្តុះបណ្តាល ឬអធិការកិច្ច។ ទោះជាយ៉ាងនេះក្តី ការសង្កេតលើវិស័យនេះបានកំណត់នូវគំនិតផ្តួចផ្តើម និងសកម្មភាពគាំទ្រមួយចំនួនដែលធ្វើឡើងដោយមន្ទីរអប់រំ យុវជន និងកីឡាក្នុងខេត្តបាត់ដំបង៖

    ក. ការិយាល័យរដ្ឋបាលបានបង្កើតក្រុម Telegram ក្រៅផ្លូវការ ដើម្បីទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធដល់រដ្ឋបាលក្រុង ស្រុកទាំងអស់។ ក្រុមនេះរួមមានអភិបាលក្រុង ស្រុក អភិបាលរងក្រុង ស្រុក ដែលទទួលខុសត្រូវលើវិស័យអប់រំ និងនាយករដ្ឋបាលក្រុង ស្រុក។

    ខ. នៅក្នុងកម្មវិធីដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុប ការិយាល័យគណនេយ្យ និងរតនាគារបានធ្វើដំណើរទៅកាន់ស្រុកមួយចំនួន (ឧទាហរណ៍ ស្រុកកំរៀង ភ្នំព្រឹក សំពៅលូន ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១) ដើម្បីបណ្តុះបណ្តាលបុគ្គលិកនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក អំពីរបៀបរៀបចំផែនការថវិកាសម្រាប់ផ្គត់ផ្គង់គ្រឹះស្ថានអប់រំ។

    គ. ការិយាល័យផែនការបានធ្វើការស្ទង់មតិ ដើម្បីកែលម្អការណែនាំ អំពីរបៀបបង្កើតផែនការប្រចាំឆ្នាំ ដូច្នេះការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក អាចធ្វើវាបានដោយខ្លួនឯង។ វាក៏បានធ្វើសិក្ខាសាលាមួយចំនួនផងដែរ ដើម្បីបង្ហាញអំពីរបៀបបង្កើតផែនការអប់រំជាយុទ្ធសាស្ត្រ ២០១៩-២០២៣ ដែលអាចបញ្ចូលទៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក និងដើម្បីតម្រង់ទិស និងធ្វើឱ្យ

ផែនការសកម្មភាពប្រចាំឆ្នាំ ២០២២ របស់ការិយាល័យអប់រំ យុវជន និងកីឡានៃ រដ្ឋបាលក្រុង ស្រុក។

ឃ. ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល បានធ្វើសិក្ខាសាលាតាមអនឡាញមួយ ដើម្បីបង្ហាញពីរបៀបគ្រប់គ្រងគ្រូច្រើនថ្នាក់1 គ្រូបង្រៀនពីរវេន2 និងបុគ្គលិក/គ្រូបង្រៀនជាប់កិច្ចសន្យា។

ង. ដោយមានការណែនាំពីក្រសួងអប់រំ យុវជន និងកីឡា និងការគាំទ្រពីអង្គការយូនីសេហ្វ ការិយាល័យអប់រំកុមារតូច បានផ្តល់វគ្គបណ្តុះបណ្តាល អំពីរបៀបបង្កើតក្រុមយុទ្ធសាស្ត្រសហគមន៍សាលារៀន និងគណៈកម្មាធិការគ្រប់គ្រងមត្តេយ្យសិក្សា នៅតាមរដ្ឋបាលក្រុង ស្រុកទាំងអស់។

3. ជាចុងក្រោយ នឹងមានឱនភាពហិរញ្ញវត្ថុប្រហែល ៥% ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៣ ដូចដែលបានឃើញនៅក្នុងផែនការថវិការយៈពេលបីឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ នេះអាចបង្ហាញថាមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នឹងប្រឈមមុខនឹងបញ្ហាប្រឈមបន្ថែមទៀតដើម្បីអនុវត្តផែនការប្រតិបត្តិការដែលមានស្រាប់ ដែលជះឥទ្ធិពលផ្ទាល់លើការកសាងសមត្ថភាព និងការត្រួតពិនិត្យដែលត្រូវបានកំណត់រួចហើយ។

## ៣.២ ចាត់ការគ្រប់គ្រងធនធានមនុស្សខេត្ត

ដោយអនុវត្តតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី "តួនាទី ការទទួលខុសត្រូវ និងការទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្ត និងគណៈអភិបាល ក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង និងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក" និងប្រកាសជាបន្តបន្ទាប់ រួមមានប្រកាសលេខ ៤២៧ បក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី "ការបង្កើតការិយាល័យនៅក្នុងទីចាត់ការខេត្ត ក្រុង ស្រុក និងតួនាទី ការទទួលខុសត្រូវ និងនីតិវិធីការងាររបស់ការិយាល័យនីមួយៗ" ទីចាត់ការគ្រប់គ្រងធនធានមនុស្សខេត្ត មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្ររដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងបញ្ហាទាក់ទងនឹងបុគ្គលិក។ កិច្ចសម្ភាសន៍ជាមួយនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សក្នុងសាលាខេត្តបាត់ដំបង បានបង្ហាញថា លោកមិនបានចូលរួមច្រើនក្នុងកិច្ចប្រជុំ ឬសិក្ខាសាលានាពេលថ្មីៗ

---

[1] គ្រូច្រើនថ្នាក់គឺសំដៅលើគ្រូបង្រៀនដែលបង្រៀនពីរឬបីថ្នាក់ក្នុងថ្នាក់ក្នុងពេលតែមួយ។

[2] នេះគឺសំដៅទៅលើគ្រូដែលបង្រៀនពីរវេន គឺពេលព្រឹក និងពេលរសៀល។ ជាធម្មតា គ្រូបង្រៀនតែពេលព្រឹក ឬពេលរសៀល។

នេះ ស្ដីពីការផ្ទេរមុខងារអប់រំ ឬការធ្វើបច្ចុប្បន្នភាពកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាទូទៅនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានទទួលពាក្យបណ្ដឹង និងបានកត់សម្គាល់ពីការអនុវត្តផ្សេងៗគ្នានៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្ត ជាពិសេសក្នុងការតែងតាំងនាយកគ្រឹះស្ថានអប់រំ ដែលគាត់មិនអាចផ្ដល់ចម្លើយច្បាស់លាស់នៅពេលការស្នើសុំឱ្យផ្ដល់អនុសាសន៍ពីរដ្ឋបាលក្រុង ស្រុកមួយចំនួន។ ជាធម្មតាគាត់បានស្នើឱ្យរដ្ឋបាលក្រុង ស្រុកពិគ្រោះយោបល់ជាមួយមន្ទីរមុខងារសាធារណៈខេត្ត។

ដូចដែលបានបង្ហាញក្នុងប្រអប់ទី១ ខាងក្រោម បញ្ហាក្នុងការតែងតាំងនាយកគ្រឹះស្ថានអប់រំ គឺភាគច្រើនបណ្ដាលមកពីមិនអាចអនុវត្តតាមគោលការណ៍ណែនាំ និងការណែនាំអំពីគោលនយោបាយដែលបានធ្វើបច្ចុប្បន្នភាពពីថ្នាក់ជាតិ។ នេះតម្រូវឱ្យអ្នកទទួលខុសត្រូវក្នុងការិយាល័យពាក់ព័ន្ធចងក្រង និងផ្សព្វផ្សាយគោលការណ៍ណែនាំផ្លូវច្បាប់ ដែលពាក់ព័ន្ធឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដល់បុគ្គលិកដែលពាក់ព័ន្ធនៅរដ្ឋបាលក្រុង ស្រុក។

**ប្រអប់ទី១៖ ការយល់ច្រឡំ [ផ្ទុយគ្នា?] គោលការណ៍ណែនាំស្ដីពីការតែងតាំងនាយកគ្រឹះស្ថានអប់រំ**

សេចក្ដីណែនាំលេខ ២១ ចេញដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ស្ដីពី "ការជ្រើសរើស និងតែងតាំងបុគ្គលិក" តម្រូវឱ្យបុគ្គលិកអប់រំ ៨០% ចូលរួមក្នុងដំណើរការវាយតម្លៃនៅពេលតែងតាំងនាយកគ្រឹះស្ថានអប់រំ។ ទោះជាយ៉ាងនេះក្ដី សេចក្ដីណែនាំនេះ ផ្អែកលើអនុក្រឹត្យលេខ ៤៩៧ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលត្រូវបានចាត់ទុកជាមោឃៈដោយអនុក្រឹត្យលេខ២៤០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពី "ការផ្ទេរអំណាចទៅឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌក្នុងការគ្រប់គ្រងបុគ្គលិកថ្នាក់ក្រោមជាតិ"។ ដោយផ្អែកលើអនុក្រិត្យចុងក្រោយនេះ និងព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៧៣ ស្ដីពី "លក្ខន្តិកៈពិសេសសម្រាប់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ក្រសួងមុខងារសាធារណៈ បានចេញសេចក្ដីណែនាំមួយចំនួនឱ្យលម្អិតអំពីដំណើរការគ្រប់គ្រងបុគ្គលិក ដូចដែលបានរៀបរាប់នៅក្នុងសេចក្ដីណែនាំលេខ ៧៨៨ និងលេខ ៧៨៩ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ និងលេខ ១២៣២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៨។ ទោះបីជាបែបនេះក៏ដោយ ការអនុវត្តផ្សេងគ្នាត្រូវបានសង្កេតឃើញ។ រដ្ឋបាលក្រុង ស្រុកមួយចំនួន រួមជាមួយនឹងការិយាល័យអប់រំ យុវជន និងកីឡា អាចគ្រប់គ្រងការតែងតាំងបុគ្គលិកបានយ៉ាងឆាប់រហ័សដោយគ្មានបញ្ហាអ្វីទាំងអស់។ ផ្ទុយទៅវិញ រដ្ឋបាលក្រុង ស្រុកខ្លះមិនអាចគ្រប់គ្រងដោយរលូនបានទេ ដោយសារមានការខ្វែងគំនិតគ្នាចំពោះដំណើរការតែងតាំងរវាង រដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក។ រដ្ឋបាលក្រុង ស្រុកមួយចំនួនបានសម្រេចចិត្តតែងតាំងនាយកគ្រឹះស្ថានអប់រំ ទោះបីជាមានការមិនពេញចិត្តក្នុងចំណោមគ្រូបង្រៀន និងបុគ្គលិកនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកក៏ដោយ។

### ៣.៣ មន្ទីរមុខងារសាធារណៈខេត្ត

ទំនួលខុសត្រូវសំខាន់មួយរបស់មន្ទីរមុខងារសាធារណៈខេត្ត គឺការធ្វើឱ្យស្របច្បាប់នូវដីកាដែលចេញដោយរដ្ឋបាលក្រុង ស្រុក ថាតើវាជាការតែងតាំង ជាការបណ្តេញចេញ ឬជាការធ្វើសមាហរណកម្មបុគ្គលិកថ្មី។ នៅឆ្នាំ២០២១ មន្ទីរមុខងារបានធ្វើនីត្យានុកូលកម្មដីកាចំនួន ១៧៧ រួមទាំងមានបុគ្គលិក ៥៣៣នាក់ (ស្រី២១២នាក់)។ មិនមានបញ្ហាអ្វីដែលរកឃើញក្នុងវិស័យអប់រំទេ ព្រោះរហូតមកដល់ពេលនេះមិនមានការត្អូញត្អែរអំពីការតែងតាំង ឬផ្ទេរបុគ្គលិកអប់រំនោះឡើយ។ ជាទូទៅគេសង្កេតឃើញថា ការតែងតាំងនាយកគ្រឹះស្ថានអប់រំមានភាពលឿនជាងមុន ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិអាចសម្រេចបាន ប៉ុន្តែដំណើរការតែងតាំងមានរយៈពេលយូរគួរកត់សម្គាល់ ដោយសារបញ្ហាមួយចំនួនដូចបានរៀបរាប់ក្នុងប្រអប់ទី២ ខាងក្រោម។

**ប្រអប់ទី២: ការពន្យារពេលក្នុងការតែងតាំងបុគ្គលិក**

ឧទាហរណ៍មួយគួរឱ្យកត់សម្គាល់គឺការតែងតាំងនាយកគ្រឹះស្ថានអប់រំមត្តេយ្យសិក្សា។ ដើម្បីបញ្ចប់ដំណើរការតែងតាំងដោយជោគជ័យ វាគឺជាតម្រូវការ ដែលសាលាមត្តេយ្យសិក្សាត្រូវបានទទួលស្គាល់ដោយប្រកាសពីក្រសួងអប់រំ យុវជន និងកីឡា ជាអកុសល មិនមានប្រកាសបែបនេះចំពោះសាលាមត្តេយ្យមួយចំនួនទេ។ ដូច្នេះហើយ ទោះបីជាមានបុគ្គលិកកាន់នាទីជានាយកស្តីទីអស់ជាច្រើនឆ្នាំក៏ដោយ ក៏គាត់នៅតែមិនអាចទទួលបានការតែងតាំងជានាយកគ្រឹះស្ថានអប់រំបានឡើយ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏ទទួលស្គាល់ករណីបែបនេះដែរ។ វាបានផ្តល់ព័ត៌មានមកថា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ធ្លាប់ស្នើសុំការទទួលស្គាល់បែបនេះពីក្រសួងអប់រំ យុវជន និងកីឡា តាំងពីឆ្នាំ ២០១៨ មកម្ល៉េះ ប៉ុន្តែរហូតមកដល់ពេលនេះ មិនទាន់មានការឆ្លើយតប (បទសម្ភាសន៍ជាមួយប្រធានការិយាល័យអប់រំកុមារតូច នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១)។

### ៣.៤ រដ្ឋបាលក្រុង/ស្រុក

រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន (សូមមើលឧបសម្ព័ន្ធទី៣) ក្នុងផ្នែកហិរញ្ញវត្ថុ បុគ្គលិក និងការគ្រប់គ្រងស្ថាប័នចាប់តាំងពីការិយាល័យជាច្រើនត្រូវបានធ្វើសមាហរណកម្មដោយអនុក្រឹត្យលេខ ១៨២/១៨៤។ បុគ្គលិកនៅរដ្ឋបាលក្រុង ស្រុកជួបប្រទះការខ្លាច ការបារម្ភ និងការភ័យ ដែលនេះជាលទ្ធផលនៃការកើនឡើងនៃបន្ទុកការងារ និងធនធានមានកំណត់។ ភាពច្របូកច្របល់ក៏ត្រូវបានកត់សម្គាល់ផងដែរ ខណៈពេលដែលព្យាយាមអនុវត្តអនុក្រឹត្យលេខ ១៨២/១៨៤។ ពួក

គេភាគច្រើនបានទទួលស្គាល់ថា ពួកគេជាមនុស្សថ្មីចំពោះភារកិច្ចទាំងនេះ ហើយបានលើកឡើងថា ការណែនាំច្បាស់លាស់ ឬគោលការណ៍ណែនាំបច្ចេកទេស អំពី របៀបអនុវត្តមុខងារវិស័យអប់រំដែលបានប្រគល់ នៅតែមិនទាន់មាននៅឡើយ។ ខណៈពេលដែលពួកគេរីករាយនឹងទទួលយកបន្ទុកថ្មីនេះ ពួកគេក៏បានកត់សម្គាល់នូវឧបសគ្គមួយចំនួនដូចខាងក្រោម៖

1) បញ្ហាបុគ្គលិក

បុគ្គលិកភាគច្រើនដែលទទួលខុសត្រូវសម្រាប់ការិយាល័យបុគ្គលិកនៅរដ្ឋបាលក្រុង ស្រុក គឺថ្មីសម្រាប់មុខតំណែងនេះ។ អ្នកខ្លះបានទទួលស្គាល់ថា ពួកគេមិនមានគំនិតអំពីរបៀបគ្រប់គ្រងបុគ្គលិកអប់រំ គ្រូជាប់កិច្ចសន្យា គ្រូពីរវេន ឬគ្រូច្រើនថ្នាក់នោះទេ។ រហូតមកដល់ពេលនេះ កិច្ចការដែលមានឥទ្ធិពលនៅរដ្ឋបាលក្រុង ស្រុក គឺការចេញដីកា ដើម្បីតែងតាំងនាយកគ្រឹះស្ថានអប់រំ និងគ្រូបង្រៀនថ្មី កែតម្រូវស្ថានភាពបច្ចុប្បន្នរបស់គ្រូបង្រៀន និងការដំឡើងប្រាក់ខែ។ ការត្អូញត្អែរដែលទទួលបានពីទាំងនេះគឺថា ដំណើរការមួយចំនួនមានភាពយឺតយ៉ាវ ហើយឯកសារគាំទ្រដែលគេតម្រូវក៏មានច្រើនជាងកាលពីនៅជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ជាឧទាហរណ៍ គ្រូបង្រៀនគេតម្រូវឱ្យថតចម្លងឯកសារពាក់ព័ន្ធជាច្រើន ហើយធ្វើការបញ្ជាក់នីត្យានុកូលកម្មនៅការិយាល័យសេវាច្រកចេញចូលតែមួយ មុនពេលបញ្ជូនវាទៅរដ្ឋបាលក្រុង ស្រុក។ នេះជាការចំណាយច្រើន និងចំណាយពេលវេលា។ ប៉ុន្តែរដ្ឋបាលក្រុង ស្រុក បានបញ្ជាក់ថា ពួកគេគ្រាន់តែធ្វើតាមការណែនាំប៉ុណ្ណោះ។

2) បញ្ហាហិរញ្ញវត្ថុ

ដោយសារការផ្ទេរថវិកាធ្វើឡើងមិនទាន់ពេលជាមួយនឹងការផ្ទេរបុគ្គលិកអប់រំ ជាហេតុធ្វើឱ្យមានការយឺតយ៉ាវខ្លះក្នុងការទូទាត់ប្រាក់ឧបត្ថម្ភបន្ថែមដល់បុគ្គលិកអប់រំ ឧទាហរណ៍ ប្រាក់ឧបត្ថម្ភមាតុភាពនៅដើមឆ្នាំ២០២១។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់ប្រាក់ជាបន្តបន្ទាប់បានធ្វើបន្ទាប់ពីឆ្នាំនេះ និងអ្វីៗកាន់តែប្រសើរឡើង ដោយសារថវិកាសម្រាប់មុខងារដែលបានប្រគល់ត្រូវបានបញ្ចូលក្នុងថវិការដ្ឋបាលក្រុង ស្រុក។ មិនមានបញ្ហាជាមួយថវិកាប្រតិបត្តិការរបស់សាលាទេ ដោយសារក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងផ្ទេរថវិកានេះដោយផ្ទាល់ទៅគណនីសាលាតាំងពីឆ្នាំ ២០០០។ ផ្ទុយទៅវិញ ថវិកាប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកគឺជាបញ្ហាប្រឈមមួយ។ មុនពេលផ្ទេរមុខងារ ការិយាល័យអប់រំ យុវជន និងកីឡាអាចចំណាយថវិការបស់ខ្លួន (ប្រហែល ៣០លានរៀល និងត្រូវបានចំណាយជាទម្រង់បុរេប្រទានជា ៤ ដំណាក់កាល ដែលត្រូវបានអនុម័តដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត) លើ (1) បេសកកម្មក្នុងក្រុង ស្រុក និង (2) ការផ្គត់ផ្គង់ការិយាល័យ (ទឹក ភ្លើង ក្រដាសបោះ

ពុម្ព សម្ភារសរសេរ ជាដើម)។ មូលនិធិសម្រាប់ការធ្វើដំណើរ និងបេសកកម្មនៅខាងក្រៅក្រុង ស្រុក ជាធម្មតាត្រូវបានផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក៏ធ្លាប់ផ្គត់ផ្គង់សម្ភារៈការិយាល័យ ដូចជាម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនថតចម្លង ក្រដាសបោះពុម្ពជាដើម។ តែករណីបែបនេះមិនមានទៀតទេចាប់តាំងពីការផ្ទេរមុខងារ (និងថវិកា) ទៅរដ្ឋបាលក្រុង ស្រុកត្រូវបានធ្វើឡើង។ រដ្ឋបាលក្រុង ស្រុក មានដំណើរការរៀបចំថវិកាដ៏ស្មុគស្មាញទាក់ទងនឹងការបុរេប្រទានសាច់ប្រាក់ ការទូទាត់ត្រង់ និងលទ្ធកម្ម។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកមិនអាចធ្វើដំណើរទៅក្រៅតំបន់របស់ពួកគេបានទៀតទេ ជាឧទាហរណ៍ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានៅក្នុងខេត្ត ដោយសារកង្វះប្រាក់ឧបត្ថម្ភធ្វើដំណើរ។ តម្រូវការលទ្ធកម្មក៏កាន់តែពិបាកសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដោយសារ 1. មិនមានក្រុមហ៊ុនច្រើន ដែលអាចផ្តល់សម្រង់តម្លៃគ្រប់គ្រាន់ដើម្បីបំពេញតាមនីតិវិធី និង 2. អំណាចបញ្ជាទិញត្រង់ត្រូវបានកាត់បន្ថយ។ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុក៏ត្រូវបានលើកឡើងនៅក្នុងឧបសម្ព័ន្ធទី៣ ផងដែរ។

3) ការគ្រប់គ្រងទ្រព្យសកម្ម

គោលការណ៍ណែនាំអំពីរបៀបផ្ទេរទ្រព្យសម្បត្តិសាលាទៅរដ្ឋបាលក្រុង ស្រុក មិនទាន់បានដាក់ចេញនៅឡើយទេ។ ដូច្នេះ រដ្ឋបាលក្រុង ស្រុក មានការស្ទាក់ស្ទើរក្នុងការសាងសង់ ផ្តល់មូលនិធិ ឬជួសជុលសាលារៀន ចាប់តាំងពីបានទទួលមុខងារវិស័យថ្មីនេះ។ ការិយាល័យអប់រំ យុវជន និងកីឡាបានកត់សម្គាល់ថាសាលារៀនមួយចំនួនត្រូវការការផ្គត់ផ្គង់ដូចជាតុសិស្ស និងតុការិយាល័យ ឬត្រូវការជួសជុល ប៉ុន្តែពួកគេមិនប្រាកដថាត្រូវសុំជំនួយពីអ្នកណានៅពេលនេះទេ។ ពីមុន តម្រូវការទាំងនេះត្រូវបានផ្តល់មូលនិធិដោយមន្ទីរអប់រំ យុវជន និងកីលាខេត្ត ប៉ុន្តែចាប់តាំងពីមុខងារត្រូវបានផ្ទេរ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាធម្មតាបានស្នើឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ទាក់ទងសុំទៅរដ្ឋបាលក្រុង ស្រុក សម្រាប់បញ្ហានេះ។ ម្យ៉ាងវិញទៀត រដ្ឋបាលក្រុង ស្រុក បានបដិសេធមិនផ្តល់មូលនិធិ ដោយសារមិនមានថវិកាគ្រោងឡើងសម្រាប់ករណីពិសេសបែបនេះ។

4) ទំនាក់ទំនងការងារ និងនីតិវិធី

បញ្ហាស្តង់ដារដូចជាការប្រើប្រាស់ត្រា និងទម្រង់រដ្ឋបាលមិនទាន់ត្រូវបានកំណត់ និងប្រើប្រាស់ជាប្រព័ន្ធនៅឡើយទេ។ រដ្ឋបាលក្រុង ស្រុក មានការស្ទាក់ស្ទើរក្នុងការអនុញ្ញាតឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ប្រើត្រារបស់ខ្លួនដើម្បីទំនាក់ទំនងខាងក្នុង (ឧ. ទៅសាលារៀន) លើមុខងារដែលបានប្រគល់ និងខាងក្រៅ (ឧ. ទៅដៃគូអភិវឌ្ឍន៍) លើមុខងារដែលបានប្រតិភូកម្ម ដូចដែលពួកគេធ្លាប់ធ្វើកន្លង

មក។ ទោះបីជាក្រសួងមហាផ្ទៃ បានចេញសេចក្តីជូនដំណឹងលេខ ១៦២២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០២០ ស្តីពី "ការពង្រឹងការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក និងខណ្ឌ" ក៏ដោយ ក៏សំណួរនៅតែមានថា តើអាចអនុវត្តបានឬអត់ ចំពោះមុខងារអប់រំ ដោយសារ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងគ្រឹះស្ថានអប់រំមានត្រាផ្ទាល់ខ្លួន។ រដ្ឋបាលក្រុង ស្រុកមួយចំនួនបានធ្វើមិនដឹងមិនឮនឹងការអនុវត្តរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក នៅពេលដែលពួកគេបន្តប្រើត្រាការិយាល័យរបស់ពួកគេដើម្បីទំនាក់ទំនងផ្ទៃក្នុងទៅកាន់គ្រឹះស្ថានអប់រំ និងដៃគូ ប៉ុន្តែរដ្ឋបាលក្រុង ស្រុកមួយចំនួនបានទាមទារយ៉ាងតឹងរ៉ឹងថាត្រាមិនត្រូវបានប្រើក្នុងបញ្ហាណាមួយឡើយ។

ការពន្យារពេលបែបការិយាធិបតេយ្យ ត្រូវបានគេសង្កេតឃើញលើការប្រើប្រាស់ទម្រង់ស្នើសុំផ្លូវការ ឬលិខិតពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ទៅរដ្ឋបាលក្រុង ស្រុក។ រដ្ឋបាលក្រុង ស្រុកមួយចំនួនទាមទារការកែតម្រូវម្តងហើយម្តងទៀតលើលិខិតស្នើសុំ ដោយមិនផ្តល់ទម្រង់ច្បាស់លាស់ណាមួយឡើយ។ ដូច្នេះ មានការពន្យារពេលដែលមិនចាំបាច់លើសំណើ ឧទាហរណ៍ សម្រាប់ការកែសម្រួលប្រាក់ខែ ឬប្រាក់ឧបត្ថម្ភបេសកកម្ម។

ការអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកក៏ជាស្ថានភាពគួរឱ្យកត់សម្គាល់ផងដែរ។ អនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពី "នីតិវិធីនៃការឈប់សម្រាក និងការអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកគ្រប់ប្រភេទសម្រាប់មន្ត្រីរាជការក្នុងប្រទេសកម្ពុជា" មានការគូសបញ្ជាក់អំពីរបៀបដែលមន្ត្រីរាជការអាចសុំច្បាប់ឈប់សម្រាកពីអ្នកគ្រប់គ្រងរបស់ពួកគេ។ បន្ទាប់ពីអនុក្រឹត្យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសារាចរណែនាំលេខ ៣ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ ដោយពណ៌នាលម្អិតអំពីអ្វីដែលត្រូវធ្វើ ដើម្បីសុំការអនុញ្ញាតច្បាប់ក្នុងវិស័យអប់រំ។ យោងតាមសេចក្តីសម្រេចលេខ ១០០២៩ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ក្រសួងក៏បានបោះពុម្ពសៀវភៅណែនាំស្តីពី "កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ" ដោយលើកឡើងពីរបៀបដែលបុគ្គលិកអាចស្នើសុំការឈប់សម្រាកពីការងារ។ នៅពេលផ្ទេរមុខងារអប់រំទៅរដ្ឋបាលក្រុង ស្រុក ពាក្យ "អ្នកគ្រប់គ្រង" នៅក្នុងឯកសារខាងលើគឺច្បាស់សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ប៉ុន្តែមិនសម្រាប់គ្រូបង្រៀន និងនាយកគ្រឹះស្ថានអប់រំនោះទេ។ មុនពេលផ្ទេរ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីអនុម័តលើការសុំច្បាប់ឈប់សម្រាករបស់គ្រូបង្រៀន និងនាយកគ្រឹះស្ថានអប់រំ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីការផ្ទេរនេះ ទោះបីជារដ្ឋបាលក្រុង ស្រុកមួយចំនួនបានអនុញ្ញាតឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកបន្តការអនុវត្តដូចពីមុន (លើកលែងតែពួកគេត្រូវដាក់ជូន រដ្ឋបាលក្រុង ស្រុកសម្រាប់ការ

អនុម័តជំនួសឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក) រដ្ឋបាលក្រុង ស្រុកខ្លះកំណត់កាតព្វកិច្ចឱ្យដាក់រាល់ការសុំច្បាប់ឈប់សម្រាកគ្រប់ប្រភេទជូនរដ្ឋបាលក្រុង ស្រុកដោយផ្ទាល់។ នេះមានន័យថាការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកមិនមានសិទ្ធិអំណាចទៀតទេក្នុងការអនុញ្ញាតឱ្យមានការឈប់សម្រាកណាមួយដល់នាយកគ្រឹះស្ថានអប់រំ និងគ្រូបង្រៀន ដូចដែលពួកគេធ្លាប់បានធ្វើនាពេលកន្លងមក។

ការប្រាស្រ័យទាក់ទងរវាងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងរដ្ឋបាលក្រុង ស្រុកក៏ត្រូវបានរកឃើញថាមានការប្រឈមផងដែរ។ រដ្ឋបាលក្រុង ស្រុកដែលជាកន្លែងដែលទំនាក់ទំនងរវាងប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងអភិបាលក៏ដូចជានាយករដ្ឋបាលត្រូវបានគេរាយការណ៍មកថា មានលក្ខណៈកាន់តែប្រសើរឡើង ប្រតិបត្តិការត្រូវបានគេមើលឃើញថាដំណើរការយ៉ាងរលូន។ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកមួយចំនួនដែលយើងបានជួប បានសម្តែងការព្រួយបារម្ភថា ពួកគេមិនប្រាកដថាអនាគតនឹងទៅជាយ៉ាងណា ប្រសិនបើមានអភិបាលថ្មី។ នៅពេលយើងសួរថា តើពួកគេនឹងទៅរកអ្នកណា ពេលជួបការលំបាកក្នុងការដោះស្រាយបញ្ហា ការិយាល័យនីមួយៗបានចង្អុលទៅស្ថាប័នផ្សេងៗគ្នា។ ខណៈពេលដែលការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ចង្អុលទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត រដ្ឋបាលក្រុង ស្រុកចង្អុលទៅមន្ទីរមុខងារសាធារណៈខេត្ត និងទីចាត់ការគ្រប់គ្រងធនធានមនុស្សខេត្ត។

5) ចំណេះដឹងរបស់សមាជិកក្រុមប្រឹក្សា

សម្រាប់មុខងារទាំងអស់ដែលត្រូវបានផ្ទេរទៅកម្រិតក្រុង ស្រុក ក្រុមប្រឹក្សាក្រុង ស្រុកនឹងត្រូវទទួលខុសត្រូវ ឧ. ក្នុងការកំណត់អាទិភាព និងការផ្តល់ថវិកា។ ដូចគ្នានេះដែរ ភ្នាក់ងាររដ្ឋបាល (ដូចជា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក) ដែលធ្វើការបញ្ចេញមុខងារក្រុង ស្រុក នឹងក្លាយជាអ្នកមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាក្រុង ស្រុក។ ទោះបីជាយ៉ាងណាក៏ដោយ ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុកស្ទើរតែទាំងអស់ដែលបានជួបបាននិយាយថា ពួកគាត់មិនត្រូវបានគេផ្តល់ព័ត៌មានល្អគ្រប់គ្រាន់អំពីការផ្ទេរមុខងារអប់រំនេះទេ។ សំណួរសួរថា អ្វីដែលល្អ អ្វីដែលមិនល្អ និងអ្វីដែលត្រូវកែលម្អ គឺវាហួសពីសមត្ថភាពគិតរបស់ពួកគាត់។ ពួកគេគ្រាន់តែដឹងថាមុខងារអប់រំត្រូវបានផ្ទេរតាមរយៈអនុក្រឹត្យលេខ ១៨២-១៨៤ ប៉ុន្តែពួកគាត់គ្មានគំនិតគិតដល់ថា តើមុខងារទាំងនេះត្រូវបានអនុវត្តយ៉ាងដូចម្តេច និងការផ្ទេរមុខងារក្នុងវិស័យនេះមានជាប់ពាក់ព័ន្ធអ្វីខ្លះដល់ក្រុមប្រឹក្សា។ ពួកគាត់ភាគច្រើនបាននិយាយថា ការិយាល័យអប់រំ យុវជន

និងកីឡាក្រុង ស្រុកធ្វើការតែជាមួយអភិបាលក្រុង ស្រុក និងអភិបាលរងក្រុង ស្រុកតែប៉ុណ្ណោះ មិនមែនជាមួយក្រុមប្រឹក្សាទេ។ ទោះជាយ៉ាងណាក៏ដោយ ស្រុកចំនួនពីរដែលបានពិពណ៌នានៅក្នុងប្រអប់ទី៣ និងប្រអប់ទី៤ បានចាប់ផ្តើមទទួលបានសមាជិកក្រុមប្រឹក្សាចូលរួមដោយធ្វើការចេញសេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ដែលទទួលខុសត្រូវចំពោះការផ្ទេរមុខងារអប់រំ។ គួរឱ្យចាប់អារម្មណ៍ គណៈកម្មាធិការមានតំណាងជាប់ឆ្នោត (ឧទាហរណ៍ សមាជិកក្រុមប្រឹក្សា) និងមន្ត្រីរដ្ឋបាល ដូចជាអភិបាលរង ឬប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកជាដើម។

**ប្រអប់ទី៣៖ គណៈកម្មការទ្រទ្រង់ថ្មគោល**

ប្រធានក្រុមប្រឹក្សាស្រុកថ្មគោល បានចេញសេចក្តីសម្រេចលេខ ០២៦/២១ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០២១ ស្តីពី "ការបង្កើតគណៈកម្មាធិការគាំទ្រដំណើរការផ្ទេរមុខងារអប់រំ"។ គណៈកម្មាធិការនេះមានសមាជិក២៣រូប រួមទាំងមេឃុំទាំងអស់ និងសមាជិកក្រុមប្រឹក្សាមួយចំនួន។ គណៈកម្មាធិការនេះដឹកនាំដោយអភិបាលរងទទួលបន្ទុកវិស័យអប់រំ។ សមាជិកក្រុមប្រឹក្សា១រូបត្រូវបានចាត់តាំងជាអនុប្រធាន ហើយប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកគឺជាអនុប្រធានអចិន្ត្រៃយ៍។ សេចក្តីសម្រេចនេះក៏បង្ហាញពីតួនាទី ទំនួលខុសត្រូវ និងនីតិវិធីការងារសំខាន់ៗផងដែរ។ ការងារសំខាន់ៗមួយចំនួន គឺគណៈកម្មាធិការធ្វើការស្រាវជ្រាវ និងចងក្រងក្របខ័ណ្ឌច្បាប់ និងគោលការណ៍ណែនាំពាក់ព័ន្ធ សិក្សាពីបញ្ហាប្រឈមដែលបានរកឃើញក្នុងអំឡុងពេលអនុវត្ត និងដោះស្រាយបញ្ហាដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន។ គណៈកម្មាធិការត្រូវមានផែនការប្រតិបត្តិការ ផែនការថវិកា និងផែនការការងារជាក់ស្តែង។ ក្នុងកិច្ចប្រជុំប្រកាសសុពលភាព នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ទាំងប្រធានក្រុមប្រឹក្សា និងអភិបាលស្រុក បានកំណត់ថា ពួកគាត់នឹងដំណើរការគណៈកម្មាធិការដោយយកចិត្តទុកដាក់ ព្រោះនេះជាលើកទី១ និងជាស្រុកដំបូងគេ ដែលត្រៀមខ្លួនរួចរាល់ក្នុងការទទួលបន្ទុកអនុវត្តមុខងារអប់រំដែលបានផ្ទេរ។ នៅពេលសរសេរឯកសារនេះ គណៈកម្មាធិការបានប្រជុំជាលើកទីពីររួចហើយ ដើម្បីកំណត់កាលវិភាគប្រជុំប្រចាំខែ និងផែនការសកម្មភាព។

**ប្រអប់ទី៤៖ គណៈកម្មាធិការគាំទ្រ ស្រុកបាណន់**

ដូចថ្នាក់គោលដែរ សេចក្តីសម្រេចចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពី "ការបង្កើតគណៈកម្មាធិការដឹកនាំ និងគ្រប់គ្រងក្នុងមុខងារអប់រំដែលបានផ្ទេរ" ត្រូវបានដាក់ចេញនៅស្រុកបាណន់។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានក្រុមប្រឹក្សាស្រុក និងមានអភិបាលរងម្នាក់ទទួលខុសត្រូវលើវិស័យអប់រំ និងសមាជិកក្រុមប្រឹក្សាមួយចំនួនជាអនុប្រធាន។ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការ រួមគ្នានឹងមេឃុំទាំងអស់នៅក្នុងស្រុកក៏ជាសមាជិក។ មិនខុសគ្នាច្រើនពីគណៈកម្មាធិការដែលបង្កើតឡើងនៅថ្នាក់គោលនោះទេ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគឺត្រូវសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធផ្សេងៗនៅក្នុងស្រុក ដើម្បីធ្វើឱ្យប្រាកដថាសេវាអប់រំត្រូវបានផ្តល់ដោយស្មើភាព និងប្រសិទ្ធភាព។ គណៈកម្មាធិការបានបើកកិច្ចប្រជុំរបស់ខ្លួននៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ដែលវាបានបង្កើតក្រុម Telegram ដែលសមាជិកទាំងអស់ត្រូវបានដាក់បញ្ចូលក្នុងក្រុមនេះ។ វាត្រូវបានសម្រេចផងដែរថា សមាជិកនីមួយៗត្រូវអានអនុក្រឹត្យលេខ ១៨២-១៨៤ ហើយត្រៀមខ្លួនដើម្បីពិភាក្សាក្នុងកិច្ចប្រជុំខាងមុខនេះ។ ពួកគេមានគម្រោងបង្កើតកាលវិភាគប្រជុំប្រចាំខែជាក់ស្តែង និងផែនការសកម្មភាពក្នុងខែខាងមុខនេះផងដែរ។

## ៣.៥ ការសង្កេត និងការវាយតម្លៃ

ជាមួយនឹងការផ្ទេរមុខងាររបស់វិស័យ តួនាទីរបស់រដ្ឋបាលក្រុង ស្រុកជាអ្នកដើរតួនាទីក្នុងស្ថាប័នក្នុងការធ្វើផែនការ ការសម្របសម្រួល និងធ្វើការប្រតិបត្តិគោលនយោបាយនៅកម្រិតក្រុង ស្រុកកាន់តែមានសារៈសំខាន់។ ការសង្កេត និងកិច្ចសម្ភាសន៍ក្នុងវិស័យនេះ បង្ហាញពីបញ្ហាប្រឈមដែលរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងកំពុងប្រឈមមុខក្នុងការអនុវត្តទំនួលខុសត្រូវថ្មី ជាមួយនឹងកម្រិតចំណេះដឹង និងធនធាននៅមានកម្រិតនៅឡើយ។ វាក៏ច្បាស់ដែរថា ក្របខ័ណ្ឌបទប្បញ្ញត្តិនៃការផ្ទេរមិនទាន់ពេញលេញ

នៅឡើយ ហើយរដ្ឋបាលក្រុង ស្រុក នៅតែកំពុងសិក្សាពីរបៀបដោះស្រាយ និងធ្វើអន្តរកម្មជាមួយគ្នា។ ខណៈពេលដែលរដ្ឋបាលក្រុង ស្រុកកំពុងពង្រឹងខ្លួនឯងដោយបំពាក់បុគ្គលិកថ្មី វាមានការលំបាកក្នុងការអនុវត្តមុខងារអប់រំ ដោយមិនមានការណែនាំច្បាស់លាស់ និងការគាំទ្រមានកំណត់។

ក្នុងពេលជាមួយគ្នានេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត នៅតែជាតួអង្គសំខាន់សម្រាប់គាំទ្រដំណើរការអនុវត្ត។ ខណៈពេលដែលវាធ្លាប់អនុវត្តមុខងារបែបនេះពីមុនមក ឥឡូវនេះវាត្រូវការធនធានមនុស្ស និងចំណេះដឹងពីស្ថាប័ននេះ សម្រាប់គាំទ្រ និងណែនាំរដ្ឋបាលក្រុង ស្រុក។ លោកនាយក១រូបនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានប្រាប់យើងថា គាត់ត្រៀមខ្លួនរួចជាស្រេចក្នុងការគាំទ្ររដ្ឋបាលក្រុង ស្រុក នៅពេលដែលមានការស្នើសុំ ឬការណែនាំពីអាជ្ញាធរពាក់ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ មិនមានយន្តការផ្លូវការដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្ររដ្ឋបាលក្រុង ស្រុកក្នុងលក្ខណៈដែលមាននិរន្តរភាពនោះទេ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តខ្លួនឯងកំពុងរង់ចាំដើម្បីទទួលបានភាពច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវ ដែលបានកែប្រែសម្រាប់ខ្លួនឯង បន្ទាប់ពីការផ្ទេរមុខងារតាមវិស័យទៅកម្រិតក្រុង ស្រុក។

គំនិតផ្តួចផ្តើមបង្កើតគណៈកម្មាធិការក្រុមប្រឹក្សា ដើម្បីគាំទ្រដល់ការអនុវត្តមុខងារអប់រំដែលបានផ្ទេរ ដូចដែលបានឃើញនៅស្រុកថ្មគោល និងស្រុកបាណន់ គឺមានសញ្ញាបង្ហាញពីភាពជោគជ័យនៅពេលអនាគត។ នេះបង្ហាញថា រដ្ឋបាលក្រុង ស្រុកកំពុងទទួលយកតួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងការអប់រំ និងចាត់វិធានការគាំទ្រយ៉ាងសកម្ម ដោយមិនរង់ចាំការណែនាំពីថ្នាក់លើនៃរដ្ឋាភិបាល។

## ៤. មេរៀនដែលបានសិក្សា និងអនុសាសន៍

ផ្អែកលើអ្វីដែលបានកើតឡើងនៅក្នុងខេត្តបាត់ដំបង យើងអាចផ្តល់នូវមេរៀន និងអនុសាសន៍ខាងក្រោម ដើម្បីយកមកពិចារណាក្នុងការកែលម្អដំណើរការអនុវត្ត និងរៀបចំសម្រាប់ការដាក់ឱ្យដំណើរការទៅកាន់ខេត្តផ្សេងទៀតនាពេលអនាគត។

## ៤.១ មេរៀន

មេរៀនទី១: គោលដៅនៃការផ្ទេរមុខងារអប់រំត្រូវតែមានការប្រាស្រ័យទាក់ទងយ៉ាងច្បាស់លាស់ជាពិសេសចំពោះអ្នកដែលអនុវត្តមុខងារដោយផ្ទាល់

ការអនុវត្តដោយរលូន នៃគោលនយោបាយថ្មីណាមួយ តម្រូវឱ្យអ្នកគ្រប់គ្នានៅក្នុងយន្តការយល់ដឹងពីគោលនយោបាយថ្មីនោះ។ ខណៈពេលដែលការសង្កេត និងកិច្ចសម្ភាសន៍ក្នុងវិស័យនេះបង្ហាញថាបុគ្គលិកនៃការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក តែងតែមិនសប្បាយចិត្តជាមួយនឹងដំណើរការផ្ទេរការគ្រប់គ្រង និងការដឹកនាំនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក តែពួកគេទទួលស្គាល់ថាការផ្លាស់ប្តូរនេះគឺជាការចាំបាច់ និងមានប្រយោជន៍សម្រាប់ធ្វើឱ្យសេវាអប់រំកាន់តែល្អប្រសើរឡើងនៅកម្រិតសហគមន៍មូលដ្ឋាន។ ដើម្បីរក្សាតុល្យភាពជាយុទ្ធសាស្ត្រទាំងបរិយាកាសការងារ និងការគាំទ្រ អ្នកគ្រប់គ្នាដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការផ្ទេរមុខងារអប់រំទៅឱ្យកម្រិតរដ្ឋបាលក្រុង ស្រុកនេះ ចាំបាច់ត្រូវទទួលបានការជូនដំណឹងយ៉ាងច្បាស់អំពីអត្ថប្រយោជន៍ដែលបានរំពឹងទុក និងអំពីដំណើរការ និងនីតិវិធីដែលបានកែប្រែ ដូច្នេះដំណើរការអនុវត្តនឹងកាន់តែប្រកបដោយបរិយាប័ន្ន និងមានប្រសិទ្ធភាព។ នេះតម្រូវឱ្យមានការលើកកម្ពស់ការយល់ដឹងឱ្យបានច្រើន និង/ឬនេះជាយុទ្ធសាស្ត្រចែករំលែកព័ត៌មានមិនត្រឹមតែជាមួយមន្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមួយសហគមន៍មូលដ្ឋានផងដែរ ដោយចាប់ផ្តើមពីគណៈកម្មាធិការគាំទ្រគ្រឹះស្ថានអប់រំ មេឃុំ/ចៅសង្កាត់ និងក្រុមប្រឹក្សាឃុំ/សង្កាត់ រហូតដល់ក្រុមប្រឹក្សាក្រុង/ស្រុក។

មេរៀនទី២: បញ្ហាទំនាក់ទំនងផ្ទាល់ខ្លួន

ទោះបីជាមិនមានការណែនាំ និងយន្តការគាំទ្រច្បាស់លាស់ក៏ដោយ បុគ្គលិកភាគច្រើននៅរដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកបានបង្ហាញថាពួកគេអាចធ្វើការជាមួយគ្នាបានយ៉ាងល្អដោយផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួន។ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកមួយចំនួនពេញចិត្តនឹងវិធីដែលពួកគេអង្គុយធ្វើការរួមគ្នាជាមួយគណៈអភិបាលក្រុង ស្រុក។ ការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់គ្នាទៅវិញទៅមក ជួយសម្រួលដល់ការបញ្ចប់ការងារ ដូចជាការចេញដីកា ការអនុម័តលើសំណើថវិកា និងការចុះហត្ថលេខាលើឯកសារនានា។ រដ្ឋបាលក្រុង ស្រុកមួយចំនួនបានរាយការណ៍ពីការខ្វះការយល់ដឹងពីគ្នាទៅវិញទៅមក ឬសូម្បីតែអារម្មណ៍នៃការអន់ចិត្ត។ មានករណីមួយចំនួនដែលរដ្ឋបាលក្រុង ស្រុកត្រូវបានគេរកឃើញថាគ្រប់គ្រងយ៉ាងតឹងរ៉ឹងលើការិយាល័យអប់រំ

យុវជន និងកីឡាក្រុង ស្រុក លើការចេញចូលក្នុងការិយាល័យ និងការប្រើប្រាស់ឧបករណ៍នៅក្នុងការិយាល័យ។ ជាឧទាហរណ៍ បុគ្គលិកនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកត្រូវបានស្នើសុំឱ្យចុះហត្ថលេខាលើឯកសារចូល និងចេញនៅការិយាល័យស្រុក បួនដងក្នុងមួយថ្ងៃ។ សម្ភារៈបរិក្ខារ ដែលស្នើសុំដោយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកមិនត្រូវបានផ្តល់ឱ្យតាមតម្រូវការទេ។ ខណៈពេលដែលរដ្ឋបាលក្រុង ស្រុកមួយចំនួនផ្គត់ផ្គង់បរិក្ខារដោយសណ្តោសប្រណីច្រើន ខ្លះទាមទារឱ្យមានការស្នើសុំឱ្យឆ្លងកាត់ដំណើរការលទ្ធកម្មដែលមិនសូវជំនឿចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ទាំងនេះវាហាក់បីដូចជាបញ្ហាកើតឡើងធម្មតា នៅពេលមានការរៀបចំស្ថាប័នថ្មី និងការដាក់ឱ្យដំណើរការនៃអាណត្តិថ្មីរបស់ស្ថាប័ន។ បញ្ហាទាំងនេះត្រូវបានរំពឹងថានឹងលែងត្រូវការដោះស្រាយតទៅទៀត នៅពេលដែលមន្ត្រីបង្កើនការយល់ដឹងរបស់ពួកគេអំពីនីតិវិធី និងការទទួលខុសត្រូវថ្មីនេះ។

### មេរៀនទី៣: ភាពមិនច្បាស់លាស់គឺជាគន្លឹះនៃការអនុវត្តគោលនយោបាយគ្មានប្រសិទ្ធភាព

សកម្មភាពធ្វើលើសជ្រុល ត្រូវបានគេមើលឃើញនៅពេលដែលអាជ្ញាធរអនុវត្តភារកិច្ចលើសពីអំណាចស្របច្បាប់របស់ពួកគេ។ ប៉ុន្តែនៅពេលដែលនរណាម្នាក់មិនហ៊ានធ្វើសកម្មភាពស្របតាមការទទួលខុសត្រូវរបស់ខ្លួន (ក្រោមអំណាចត្រឹមត្រូវ ឬនៅក្នុងអំណាច) ជាធម្មតាត្រូវបានគេបន្ទោសថាមកពីការណែនាំ និងគោលការណ៍ច្បាប់មិនច្បាស់លាស់។ ទោះបីជាគោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីរដ្ឋបាលលម្អិតចាំបាច់ត្រូវតែបង្កើតបន្ថែមទៀតក៏ដោយ ក៏អនុក្រឹត្យលេខ ១៨២-១៨៤ បានគូសបញ្ជាក់រួចហើយពីអ្វីដែលរដ្ឋបាលក្រុង ស្រុកអាចធ្វើបានដើម្បីអនុវត្តមុខងារអប់រំ។ ជាឧទាហរណ៍ មាត្រា ៣០ ក្នុងអនុក្រឹត្យលេខ ១៨២ និង ១៨៤ អនុញ្ញាតឱ្យរដ្ឋបាលក្រុង ស្រុកបង្កើតក្រុមការងារដែលទទួលខុសត្រូវចំពោះវិស័យជាក់លាក់មួយ។ ទោះបីជាខ្លឹមសារច្បាប់មានភាពច្បាស់លាស់ហើយក៏ដោយ ប៉ុន្តែរដ្ឋបាលក្រុង ស្រុកមួយចំនួននៅតែស្ទាក់ស្ទើរក្នុងការធ្វើតាមនោះ ហើយជំនួសមកវិញពួកគេបានសម្រេចចិត្តរង់ចាំការណែនាំបន្ថែម។ អ្នកខ្លះព្រួយបារម្ភថាពួកគេនឹងប្រព្រឹត្តហួសពីអំណាចផ្លូវច្បាប់ ឬពួកគេគ្មានសិទ្ធិអំណាចសម្រេច។

កង្វះភាពច្បាស់លាស់កំពុងផ្តល់ឱ្យមានការបកស្រាយផ្សេងៗគ្នា ហើយការអនុវត្តក៏ដូច្នេះដែរ។ ការប្រើប្រាស់ត្រានៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកគឺជាឧទាហរណ៍មួយនៅទីនេះ៖ មានការបកស្រាយខុសៗគ្នានៃសេចក្តីណែនាំលេខ ១៦២២ របស់ក្រសួងមហាផ្ទៃ។ វាត្រូវបានរាយការណ៍ថា

ការជូនដំណឹងអំពីបទប្បញ្ញត្តិគឺមិនច្បាស់លាស់ទាក់ទងនឹងមុខងារអប់រំ ដូច្នេះហើយ វាមានចម្ងល់ថាតើការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកអាចប្រើត្រាបានដែរឬអត់ ហើយប្រសិនបើត្រាអាចត្រូវបានប្រើទាក់ទងនឹងមុខងារប្រតិភូកម្ម វាខុសអ្វីនឹងមុខងារផ្ទេរប្រគល់។ ការអនុវត្តហាក់ដូចជាខុសគ្នាពីស្រុកមួយទៅស្រុកមួយទៀត។ អ្នកខ្លះឈប់ប្រើត្រាទាំងស្រុង អ្នកខ្លះទៀតនៅតែប្រើវាសម្រាប់ឯកសារផ្ទៃក្នុង ហើយអ្នកផ្សេងទៀតបន្តប្រើវាទាំងផ្ទៃក្នុង និងផ្ទៃក្រៅតាមករណីនីមួយៗ។

ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ខេត្តដែលពាក់ព័ន្ធ (ដូចជាក្រសួងវិស័យ) មានការយឺតយ៉ាវក្នុងការឆ្លើយតប។ ទោះបីជាមានផែនការយុទ្ធសាស្ត្រដើម្បីពិនិត្យមើលឡើងវិញ និងបង្កើតឧបករណ៍ និងយន្តការច្បាប់ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ ដូចដែលបានរំពឹងទុកនៅក្នុងគោលនយោបាយឆ្នាំ ២០១៦ របស់ខ្លួនស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ" ក៏ដោយ ក៏ក្រសួងអប់រំ យុវជន និងកីឡាមិនទាន់បានបញ្ជាក់ និងកំណត់អំពីតួនាទី និងការទទួលខុសត្រូវដែលបានធ្វើបច្ចុប្បន្នភាពរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តនៅឡើយទេ។ គោលការណ៍ណែនាំបច្ចេកទេសជាក់លាក់ស្តីពីមុខងារអប់រំដែលបានផ្ទេរក៏មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ទោះបីជាក្រុមការងារសម្រាប់គោលបំណងនេះត្រូវបានបង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ ២០២០ ក៏ដោយ។

## មេរៀនទី៤: យន្តការគាំទ្រគួរត្រូវបង្កើតឡើងនៅថ្នាក់ខេត្ត

ការត្រួតពិនិត្យស្ថាប័នខាងលើ បង្ហាញពីស្ថាប័នមួយចំនួនដែលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ។ យន្តការគាំទ្រប្រកបដោយប្រសិទ្ធភាពនឹងត្រូវបង្កើតឡើង និងប្រចាំការ ដូច្នេះការស្នើឱ្យមានការបំភ្លឺ និងគាំទ្របញ្ហាពាក់ព័ន្ធអាចត្រូវបានឆ្លើយតបភ្លាមៗ។ ចម្លើយចំពោះសំណួររបស់អ្នកឆ្លើយសំណួរ ទៅអ្នកណាដែលគេមិនច្បាស់អំពីអ្វីដែលត្រូវធ្វើជាមួយដំណើរការអនុវត្តផ្តល់លទ្ធផលចម្រុះ។ ខណៈពេលដែលបុគ្គលិករដ្ឋបាលក្រុង ស្រុក ចង្អុលទៅទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត និងមន្ទីរមុខងារសាធារណៈខេត្ត បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកនៅតែចង្អុលទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ម្យ៉ាងវិញទៀតមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាធម្មតាស្នើឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកស្តាប់រដ្ឋបាលក្រុង ស្រុក ខណៈដែលមុខងារត្រូវបានផ្ទេរទៅឱ្យពួកគេរួចហើយ។ ម្យ៉ាងវិញទៀតរដ្ឋបាលក្រុង ស្រុក ត្រូវបានស្នើសុំដោយទីចាត់ការគ្រប់គ្រង

ធនធានមនុស្សសាលាខេត្ត និងមន្ទីរមុខងារសាធារណៈខេត្ត ដើម្បីពិភាក្សាជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដើម្បីស្វែងរកដំណោះស្រាយត្រឹមត្រូវ។

ស្ថានភាពនៅរដ្ឋបាលក្រុង ស្រុកមួយ អាចត្រូវបានយកជាឧទាហរណ៍មួយ ដើម្បីពន្យល់លម្អិតអំពីបញ្ហានេះ។ ដោយលើកហេតុផលថាមុខងារអប់រំត្រូវបានផ្ទេររួចហើយ រដ្ឋបាលក្រុង ស្រុកបានធ្វើសកម្មភាពយ៉ាងក្លាហានលើបញ្ហានេះ ដោយតម្រូវឱ្យដំណើរការរដ្ឋបាលណាមួយដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ឱ្យទៅកាន់នីតិវិធីរដ្ឋបាលរបស់ រដ្ឋបាលក្រុង ស្រុក។ ចាប់ពីការអនុម័តលើការឈប់សម្រាករបស់គ្រូបង្រៀន រហូតដល់ការតែងតាំងនាយកគ្រឹះស្ថានសិក្សា ឥឡូវនេះ រដ្ឋបាលក្រុង ស្រុកទទួលបន្ទុកទាំងអស់ ហើយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកគឺត្រូវបានបដិសេធ។ ការត្អូញត្អែរអំពីរឿងនេះត្រូវបានឮនៅតាមស្ថាប័នផ្សេងៗគ្នា (ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដល់លេខាធិការដ្ឋាន គ.ជ.អ.ប) ប៉ុន្តែការបំភ្លឺជាក់លាក់ ឬការសម្របសម្រួលមិនទាន់ត្រូវបានធ្វើឡើងនៅឡើយ។

ជាការពិតណាស់ ស្ថានភាពពាក់ព័ន្ធនឹងបញ្ហាទាំងអស់ដែលបានរៀបរាប់ខាងលើ - ពីការណែនាំផ្លូវច្បាប់មិនច្បាស់លាស់ រហូតដល់ទំនាក់ទំនងផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ស្រមៃមើលថាតើមានក្រុមគាំទ្រដែលរួមមានអ្នកជំនាញផ្នែកអប់រំបច្ចេកទេសពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត អ្នកជំនាញធនធានមនុស្ស/បុគ្គលិកពីទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត និងជំបូន្មានផ្នែកច្បាប់ពីមន្ទីរមុខងារសាធារណៈខេត្ត នោះអ្វីៗអាចប្រសើរជាងមុន ហើយកម្រិតនៃការពេញចិត្តនឹងត្រូវបានគេសង្កេតឃើញថាខ្ពស់។ ទោះបីជារដ្ឋបាលក្រុង ស្រុកមួយចំនួនកំពុងបង្កើតគណៈកម្មាធិការដែលទទួលខុសត្រូវលើមុខងារផ្ទេរការអប់រំក៏ដោយ ក៏ក្រុមការងារស្រដៀងគ្នានៅថ្នាក់ខេត្តចាំបាច់ត្រូវបង្កើតឡើងដើម្បីគាំទ្ររដ្ឋបាលក្រុង ស្រុក យ៉ាងហោចណាស់សម្រាប់រយៈពេលជាក់លាក់មួយនៃដំណើរការអនុវត្ត។

## មេរៀនទី៥: ការកសាងសមត្ថភាពគឺជាគន្លឹះនៃភាពជោគជ័យ

ការកសាងសមត្ថភាពគឺជាយុទ្ធសាស្ត្រពង្រឹងអំណាចមួយដែលមិនត្រូវមើលរំលង នៅពេលប្រឈមមុខនឹងបញ្ហាក្នុងការអនុវត្តមុខងារអប់រំដែលទើបតែត្រូវបានផ្ទេរ។ សមត្ថភាពស្ថាប័នរួមជាមួយនឹងសមត្ថភាពបុគ្គលត្រូវការវិភាគ និងបង្កើត។

ការវាយតម្លៃតម្រូវការបណ្តុះបណ្តាល ត្រូវបានធ្វើឡើងដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយមានការគាំទ្រពីកម្មវិធីដារនៃអង្គការដើអាយហ្សិត ចាប់ពីខែកុម្ភៈ ដល់ខែមីនា ឆ្នាំ២០២១ ដោយមានអ្នកចូលរួម ២៨៦នាក់ មកពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងរដ្ឋបាលក្រុង ស្រុក៖ វាបង្ហាញថាមានជំនាញបច្ចេកទេស បច្ចេកវិទ្យា និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនដែលត្រូវដោះស្រាយ ជាមួយនឹងការគ្រប់គ្រងបុគ្គលិក ការធ្វើផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសកម្ម គឺជាអាទិភាពបីសំខាន់ (សូមមើលឧបសម្ព័ន្ធទី៣ សម្រាប់សេចក្តីសង្ខេបនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល)។ តម្រូវការបន្ទាន់សម្រាប់ការកសាងជំនាញបច្ចេកទេសត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ការបណ្តុះបណ្តាលកុំព្យូទ័រជាមូលដ្ឋាន (វាយអក្សរ ដោយប្រើប្រាស់ MS Word, Excel, និង PowerPoint)។ ជាចុងក្រោយជំនាញអភិវឌ្ឍន៍ផ្ទាល់ខ្លួនទាំងបីនេះក៏ត្រូវបានកំណត់ផងដែរសម្រាប់ការពង្រឹង៖ ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងពេលវេលា និងការទំនាក់ទំនង។

## ៤.២ អនុសាសន៍

- ការចែករំលែកព័ត៌មាន និងការលើកកម្ពស់ការយល់ដឹងត្រូវធ្វើឡើងទៅកាន់សហគមន៍មូលដ្ឋាន និងក្រុមប្រឹក្សាស្រុក/ក្រុង

ការធ្វើសិក្ខាសាលាតែមួយ ដើម្បីផ្សព្វផ្សាយអំពីអនុក្រឹត្យលេខ ១៨២-១៨៤ និង/ឬការផ្លាស់ប្តូរគោលនយោបាយនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត គឺមិនគ្រប់គ្រាន់សម្រាប់រដ្ឋបាលក្រុង ស្រុកទេ។ ការផ្ទេរមុខងារអប់រំផ្តល់តួនាទី និងការទទួលខុសត្រូវថ្មីដល់កម្រិតក្រុង ស្រុក ហើយតួអង្គសំខាន់នៅកម្រិតនេះចាំបាច់ត្រូវដឹងយ៉ាងច្បាស់អំពីការផ្លាស់ប្តូរបែបនេះ។ សិក្ខាសាលាផ្សព្វផ្សាយស្តីពីការផ្ទេរភារកិច្ចសំខាន់ៗ គួរត្រូវធ្វើនៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ ក្រៅពីធ្វើនៅថ្នាក់ខេត្ត។

- មានតម្រូវការបន្តសម្រាប់ការណែនាំ និងការអប់រំច្បាស់លាស់ជាងមុន

ការយកខេត្តបាត់ដំបងជាខេត្តសាកល្បងសម្រាប់ការអនុវត្តមុខងារអប់រំ បានជួយកំណត់បញ្ហារដ្ឋបាលមួយចំនួន ដែលចាំបាច់ត្រូវបញ្ជាក់នៅពេលចាប់ផ្តើមដំណើរការផ្ទេរ ដើម្បីជៀសវាងការភ័ន្តច្រឡំ និងកង្វះការតំរង់ទិសនៅកម្រិតរដ្ឋបាលក្រុង ស្រុក។ បញ្ហាដែលកើតមាននៅក្នុងខេត្តបាត់ដំបង (ដូចជារបៀប

និងពេលដែលត្រានៃការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកអាចត្រូវបានប្រើដើម្បីទំនាក់ទំនងក្នុង និង/ឬក្រៅគ្រឹះស្ថានអប់រំ អ្នកណាជាអ្នកអនុម័តរយៈពេលដាក់លាក់សម្រាប់ការឈប់សម្រាករបស់នាយកសាលា ឬគ្រូបង្រៀន - តើការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកឬ? ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលក្រុង ស្រុកឬ? ឬក៏អភិបាលក្រុង ស្រុក? តើមន្ទីរអប់រំ យុវជន និងកីឡាខេត្តមានតួនាទី និងការទទួលខុសត្រូវយ៉ាងដូចម្តេចទាក់ទងនឹងការគាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងរដ្ឋបាលក្រុង ស្រុក? តើការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកអាចទទួលបានថវិកាដែលត្រូវការសម្រាប់បេសកកម្មនៅខាងក្រៅស្រុក/ក្រុងទេ ដោយសាររដ្ឋបាលក្រុង ស្រុកមិនអាចគាំទ្រវាបាន?) មើលទៅសាមញ្ញ ទោះយ៉ាងណាក៏ដោយ ពួកគេបានរំខានដល់ដំណើរការអនុវត្តដោយរលូននៅកម្រិតរដ្ឋបាលក្រុង ស្រុក។ បន្ថែមពីលើការខ្វះខាតគោលការណ៍ណែនាំ និងបទប្បញ្ញត្តិដើម្បីដោះស្រាយបញ្ហាខាងលើ ភាពមិនស៊ីសង្វាក់គ្នានៃគោលការណ៍ណែនាំ និងបទប្បញ្ញត្តិដែលមានស្រាប់ ចាំបាច់ត្រូវដោះស្រាយ។

- បញ្ចប់ការតាក់តែងសៀវភៅបណ្តុះបណ្តាលមុខងារអប់រំ

រដ្ឋបាលក្រុង ស្រុក ត្រូវដឹងពីរបៀបដឹកនាំ និងគ្រប់គ្រងមុខងារអប់រំដែលត្រូវបានផ្ទេរ និងការកសាងជំនាញទាំងនោះ ទាមទារឱ្យមានការផ្តោតលើការកសាងសមត្ថភាព។ វាត្រូវបានគេយល់ថាក្រុមការងារដែលបានបង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ២០២០ និងដឹកនាំដោយសាលារដ្ឋបាលថ្នាក់ជាតិកំពុងរៀបចំសៀវភៅណែនាំបណ្តុះបណ្តាលបែបនេះ។ សម្រាប់ការដាក់ឱ្យដំណើរការបែបនេះទៅខេត្តដទៃទៀតក៏ទាមទារឱ្យមានសៀវភៅណែនាំបែបនេះផងដែរ។

- ការសម្របសម្រួលកាន់តែប្រសើរឡើងនៃស្ថាប័នពាក់ព័ន្ធ

យន្តការគាំទ្រតាមខេត្តចាំបាច់ត្រូវបង្កើតឡើងសម្រាប់ដំណាក់កាលអន្តរកាលមួយនេះ រហូតទាល់តែ រដ្ឋបាលក្រុង ស្រុកបានស្រូបយកទាំងស្រុងនូវមុខងារដែលបានផ្ទេរថ្មី ហើយមានទំនុកចិត្តក្នុងការដោះស្រាយវា។ យន្តការគាំទ្របែបនេះនឹងពាក់ព័ន្ធនឹងតំណាងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត មន្ទីរមុខងារសាធារណៈខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខេត្ត ហើយបម្រើជាវេទិកាដែលអ្នកពាក់ព័ន្ធថ្នាក់ខេត្តឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាដែលកើតឡើងនៅក្នុងដំណើរការអនុវត្តមុខងារនៅកម្រិតក្រុង ស្រុក។ យន្តការបែបនេះក៏អាចជួយសម្រួលទំនាក់ទំនង និងអន្តរកម្មជាមួយស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ (ដូចជា គ.ជ.អ.ប. ក្រសួងមុខងារសាធារណៈ និងក្រសួងវិស័យ)។ រដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកអាចផ្តោតទៅលើយន្តការឆ្លើយតបនេះ នៅពេលដែលពួកគេមានការមន្ទិលអំពីការដោះស្រាយជាមួយបញ្ហាប្រឈមក្នុងការអនុវត្ត។

- ការកសាងសមត្ថភាព

សមត្ថភាពគឺត្រូវការជាចាំបាច់ សម្រាប់ដំណើរការកំណែទម្រង់ប្រកបដោយប្រសិទ្ធភាពទាំងថ្នាក់ខេត្ត និងក្រុង/ស្រុក។ វាគឺសំខាន់ណាស់ដែលបុគ្គលិកបច្ចេកទេសនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្រូវបានបំពាក់នូវចំណេះដឹងបច្ចេកទេស និងជំនាញចាំបាច់ដើម្បីគាំទ្រដល់រដ្ឋបាលក្រុង/ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ក្នុងការអនុវត្តដំណើរការមុខងារអប់រំ។ បុគ្គលិកនៅរដ្ឋបាលក្រុង/ស្រុកក៏ត្រូវការជំនាញបច្ចេកទេស និងទំនាក់ទំនងអន្តរបុគ្គលផងដែរ ដើម្បីដឹកនាំ និងគ្រប់គ្រងកិច្ចការដែលបានប្រគល់ជូន។ ចំណេះដឹងបច្ចេកទេសផ្នែកអប់រំ និងសមត្ថភាពក្នុងការដឹកនាំក្រុម គឺជាកត្តាសំខាន់ ដើម្បីកែលម្អអាកប្បកិរិយាជាវិជ្ជមាន វាមិនមែនត្រឹមតែសម្រាប់អនុវត្តមុខងារអប់រំប៉ុណ្ណោះទេ ប៉ុន្តែដើម្បីបម្រើដល់សាធារណជនផងដែរ។

ការកសាងសមត្ថភាពនៅកម្រិតស្ថាប័នក៏មានសារៈសំខាន់ចំពោះនិរន្តរភាពផងដែរ។ ផែនការកសាងសមត្ថភាពច្បាស់លាស់គួរតែត្រូវបានបញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងរដ្ឋបាលក្រុង/ស្រុក ដើម្បីបង្កើនភាពរឹងមាំរបស់ស្ថាប័នដែលមានស្រាប់។ ស្ថាប័នរឹងមាំនឹងអាចរក្សា និងគាំទ្រដំណើរការផ្ទេរចំណេះដឹង ក៏ដូចជាការចែករំលែកចំណេះដឹងក្នុង និងទូទាំងស្ថាប័ន។

## ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះមន្ត្រីដែលបានសម្ភាសន៍

| ល.រ | ឈ្មោះ | មុខតំណែង |
|---|---|---|
| មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | | |
| 1. | យី ស៊ុងគី | ប្រធាន |
| 2. | ភួង មុន្នី | អនុប្រធាន |
| 3. | គង់ រចនា | ប្រធានការិយាល័យរដ្ឋបាល |
| 4. | ភក់ រិទ្ធា | ប្រធានការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល |
| 5. | ទៀង វិសាល | ប្រធានការិយាល័យអប់រំបឋមសិក្សា |
| 6. | ភូ វណ្ណារិទ្ធ | ប្រធានការិយាល័យផែនការ |
| 7. | រី ផល្លា | ប្រធានការិយាល័យអប់រំក្រៅប្រព័ន្ធ |
| 8. | សេង ព៉ាស៊ីន | ប្រធានការិយាល័យអប់រំកុមារតូច |
| មន្ទីរមុខងារសាធារណៈខេត្ត | | |
| 9. | ងួន យូ | ប្រធាន |
| 10. | ស រចនា | អនុប្រធាន |
| 11. | សុក ចំរើន | ប្រធានការិយាល័យក្របខណ្ឌ និងបណ្តុះបណ្តាល |
| 12. | ធុក បូរី | អនុប្រធានការិយាល័យបៀវត្ស និងបម្រែបម្រួល |
| ទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | | |
| 13. | ផៃង សារ៉ាត់ | នាយក |
| ស្រុកបាណន់ | | |
| 14. | ជុំ ញ៉ |ប្រធានក្រុមប្រឹក្សា |
| 15. | រាជ បូ៉ានី | សមាជិកក្រុមប្រឹក្សា |
| 16. | នួន ភារម្យ | អភិបាលរង |
| 17. | មៀត សីនី | នាយករដ្ឋបាល |
| 18. | ម៉ា ស្រីម៉ៅ | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| 19. | សេង សុទ្ធី | ប្រធានស្តីទីការិយាល័យបុគ្គលិក |
| 20. | ជា វង្សណារិន | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ក្រុងបាត់ដំបង | | |
| 21. | យូ សុគន្ធ | អភិបាលរង |

| | | |
|---|---|---|
| 22. | ទ្រី ហាក់ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកបវេល | | |
| 23. | សែម ពៅ | អភិបាលរង |
| 24. | សួន វែង | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកឯកភ្នំ | | |
| 25. | ផុក ស៊ីនណារី | អភិបាលរង |
| 26. | វ៉ាន់ សុឃឿន | នាយករដ្ឋបាល |
| 27. | យុត សម្បត្តិ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកគាស់ក្រឡ | | |
| 28. | ឈឿន សុភានី | អភិបាលរង |
| 29. | អ៊ូច សុវណ្ណ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកកំរៀង | | |
| 30. | សិន ណាវុទ្ធ | អភិបាលរង |
| 31. | ជឿន សុផាត | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកមោងឫស្សី | | |
| 32. | ពេជ ម៉ាឡៃ | ប្រធានក្រុមប្រឹក្សា |
| 33. | ចាប សុគុណ | សមាជិកក្រុមប្រឹក្សា |
| 34. | ទេព ហន | អភិបាល |
| 35. | ឡិក រត្នមុន្នី | អភិបាលរង |
| 36. | ហាង សុផារី | នាយករដ្ឋបាល |
| 37. | ហម សារិន | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកភ្នំព្រឹក | | |
| 38. | ប៉ុក ពុំ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| 39. | ឈិន ថា | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| 40. | ហ៊ុន លាងអាយ | ប្រធានការិយាល័យបុគ្គលិក |
| ស្រុករុក្ខគីរី | | |
| 41. | សំ តាប់ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| 42. | រឿន រ៉ាវី | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| 43. | វ៉ើត ធារ៉ា | អនុប្រធានការិយាល័យបុគ្គលិក |
| ស្រុករតនមណ្ឌល | | |
| 44. | ឌី សំអាត | អភិបាលរង |
| 45. | ណុប ប្រុស | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកសង្កែ | | |
| 46. | ស៊ីវ សុវណ្ណា | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| 47. | ណុប ចិន្តា | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| 48. | គង់ ចាន់ណារិទ្ធ | អនុប្រធានការិយាល័យបុគ្គលិក |
| ស្រុកសំឡូត | | |
| 49. | គីម ហាន | អភិបាលរង |
| 50. | សួន ធី | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកសំពៅលូន | | |
| 51. | បឿន សារឿន | អភិបាលរង |
| 52. | អាន សំអាត | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| ស្រុកថ្មគោល | | |
| 53. | ម៉ុក សុខុន | សមាជិកក្រុមប្រឹក្សា |
| 54. | បួន សារ៉ែន | សមាជិកក្រុមប្រឹក្សា |
| 55. | សាន ធុង | សមាជិកក្រុមប្រឹក្សា |
| 56. | សិង្គ សុខា | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា |
| 57. | ទន់ សុភ័ក្រ | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| 58. | ជួង ស៊ីណាង | អនុប្រធានការិយាល័យបុគ្គលិក |

## ឧបសម្ព័ន្ធទី២៖ សិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

- **សិក្ខាសាលាលើកទី១៖ សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី មុខងារ និងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក និងគោលការណ៍សម្រាប់ការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។**
- អ្នករៀបចំ៖ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធីដារ
- កាលបរិច្ឆេទ និងទីកន្លែង៖ ២៩-៣០ កក្កដា ២០២១ (ធ្វើតាមអនឡាញ/MS-Teams)

➢ គោលបំណង៖

1. ដើម្បីទទួលស្គាល់មុខងារ និងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក និងគោលការណ៍សម្រាប់អនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរ។
2. ពិភាក្សាបញ្ហាប្រឈមក្នុងការអនុវត្តមុខងារដែលបានផ្ទេរ។
3. ពិនិត្យមើលយន្តការគាំទ្រ ដើម្បីសម្របសម្រួលដំណើរការផ្ទេរមុខងារ។

➢ អ្នកចូលរួម៖

| ល.រ | ស្ថាប័ន/រដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| 1. | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | 13 | 2 | 15 |
| 2. | ស្រុកឯកភ្នំ | 4 | 1 | 5 |
| 3. | ស្រុកបាត់ដំបង | 6 | 2 | 8 |
| 4. | ស្រុកបាណន់ | 5 | 3 | 8 |
| 5. | ស្រុកបវេល | 8 | 2 | 10 |
| 6. | ស្រុកគាស់ក្រឡ | 6 | 1 | 7 |
| 7. | ស្រុកកំរៀង | 11 | 1 | 12 |
| 8. | ស្រុកមោងឫស្សី | 5 | 1 | 6 |
| 9. | ស្រុកភ្នំព្រឹក | 4 | 2 | 6 |
| 10. | ស្រុករុក្ខគីរី | 9 | 0 | 9 |
| 11. | ស្រុករតនមណ្ឌល | 4 | 3 | 7 |
| 12. | ស្រុកសង្កែ | 5 | 2 | 7 |
| 13. | ស្រុកសំឡូត | 7 | 1 | 8 |
| 14. | ស្រុកសំពៅលូន | 12 | 3 | 18 |
| 15. | ស្រុកថ្មគោល | 7 | 3 | 10 |
| **សរុប** | | **106** | **27** | **136** |

➢ **សិក្ខាសាលាទី២៖ សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអនុវត្តមុខងារអប់រំដែលបានប្រតិភូកម្ម និងប្រគល់ជូនទៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង។**

➢ អ្នករៀបចំ៖ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធីដារ។

➢ កាលបរិច្ឆេទ និងទីកន្លែង៖ ២៤ មិនា ២០២២ នៅសណ្ឋាគារក្លាស៊ី ក្នុងក្រុងបាត់ដំបង និងធ្វើតាមអនឡាញ/MS-Teams)។

➢ គោលបំណង៖

1. ឆ្លុះបញ្ចាំងការអនុវត្តនៃមុខងារអប់រំ ដែលបានប្រតិភូកម្ម និងផ្ទេរប្រគល់ជូនរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង។
2. ពិនិត្យបញ្ហាក់បទពិសោធន៍ទទួលបានពីដំណើរការអនុវត្ត។
3. ប្រមូលចងក្រងព័ត៌មានបន្ថែម និងអនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនៃមុខងារអប់រំ។

➢ អ្នកចូលរួម៖

| ល.រ | ស្ថាប័ន/រដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| 1. | តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប | 1 | 0 | 1 |
| 2. | តំណាងក្រសួងអប់រំ យុវជន និងកីឡា | 2 | 0 | 2 |
| 3. | តំណាងក្រសួងមុខងារសាធារណៈ | 1 | 0 | 1 |
| 4. | តំណាងសាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ | 1 | 0 | 1 |
| 5. | តំណាងមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | 1 | 0 | 1 |
| 6. | ស្រុកឯកភ្នំ | 3 | 1 | 4 |
| 7. | ក្រុងបាត់ដំបង | 3 | 1 | 4 |
| 8. | ស្រុកបាណន់ | 3 | 2 | 5 |
| 9. | ស្រុកបវេល | 3 | 2 | 5 |
| 10. | ស្រុកគាស់ក្រឡ | 4 | 1 | 5 |

| ល.រ | ស្ថាប័ន/រដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| 11. | ស្រុកកំរៀង | 4 | 1 | 5 |
| 12. | ស្រុកមោងឫស្សី | 4 | 1 | 5 |
| 13. | ស្រុកភ្នំព្រឹក | 4 | 1 | 5 |
| 14. | ស្រុករុក្ខគីរី | 5 | 0 | 5 |
| 15. | ស្រុករតនមណ្ឌល | 3 | 2 | 5 |
| 16. | ស្រុកសង្កែ | 3 | 2 | 5 |
| 17. | ស្រុកសំឡូត | 5 | 0 | 5 |
| 18. | ស្រុកសំពៅលូន | 4 | 1 | 5 |
| 19. | ស្រុកថ្មគោល | 4 | 1 | 5 |
| **សរុប** | | **58** | **16** | **74** |

## ឧបសម្ព័ន្ធទី៣៖ បញ្ជីបញ្ហាប្រឈម និងសំណូមពរ

| ល.រ | បញ្ហាប្រឈម | មូលហេតុ | ទិន្នន័យជាក់លាក់អំពីមន្ត្រី ឬចំនួនថវិកា ឬបុគ្គលិក | សំណើដំណោះស្រាយឬសំណូមពរ ពីរដ្ឋបាលក្រុង ស្រុក | ក្រុង ស្រុក |
|---|---|---|---|---|---|
| ការគ្រប់គ្រងបុគ្គលិក | | | | | |
| ១. | ខ្វះមន្ត្រីបម្រើការងារនៅការិយាល័យអប់រំ | ចូលនិវត្តន៍ និងទទួលមរណភាព | បើយោងតាមនិយាមប្រើប្រាស់បុគ្គលិកលេខ២០ ចុះឆ្នាំ២០១៨ ការិ.អប់រំចាំបាច់ត្រូវប្រើបុគ្គលិកចំនួន១៦-១៨នាក់ ដោយមិនរាប់បញ្ចូលទាំងប្រធាន និងអនុប្រធាន | ស្នើរដ្ឋបាលក្រុង ស្រុកសម្របសម្រួលដោះស្រាយ (លេខាធិការដ្ឋានគ.ជ.អប. នឹងពិនិត្យ ពិភាក្សាជាមួយក្រសួងអប់រំ និងក្រសួងមុខងារសាធារណៈ) | ក្រុងបាត់ដំបង<br>ស្រុករតនមណ្ឌល<br>ស្រុកបវេល<br>ស្រុកថ្មគោល |
| ២ | សាលាមួយចំនួនខ្វះគ្រូបង្រៀន ដោយឡែកសាលាមួយចំនួនមានគ្រូលើសពីនិយាមប្រើប្រាស់បុគ្គលិក | ពុំទាន់បានពង្រាយគ្រូឱ្យស្របតាមចំនួនសិស្ស | | (លេខាធិការដ្ឋានគ.ជ.អ.ប នឹងពិនិត្យ ពិភាក្សាជាមួយក្រសួងអប់រំ និងក្រសួងមុខងារសាធារណៈ) | ក្រុងបាត់ដំបង |
| ៣ | ខ្វះគ្រូបង្រៀននៅតាមសាលាគ្រឹះស្ថានសិក្សា | ចំនួនសិស្សកើនឡើង | | (លេខាធិការដ្ឋានគ.ជ.អ.ប. នឹងពិនិត្យ ពិភាក្សាជាមួយក្រសួងអប់រំ និងក្រសួងមុខងារសាធារណៈ) | ស្រុករតនៈមណ្ឌល<br>ស្រុកភ្នំព្រឹក<br>ស្រុកសំពៅលូន<br>ស្រុករុក្ខគិរិ<br>ស្រុកកំរៀង |
| ៤ | ការដំឡើថ្នាក់ និងឋានន្តរស័ក្កិ ការដំឡើងថ្នាក់ជូនគ្រូបង្រៀន និងមន្ត្រីនៅការិ.អប់រំមានការយឺតយ៉ាវ | - ចំនួនគ្រូបង្រៀន និងមន្ត្រីការិ.អរំមានចំនួនច្រើន | | (លេខាធិការដ្ឋានគ.ជ.អ.ប. ស្នើអភិបាលក្រុងស្រុកពិនិត្យជាមួយអ្នកពាក់ព័ន្ធនានាដោះស្រាយបញ្ហានេះ។) | ស្រុកសង្កែ<br>ស្រុកមោងឬស្សី |

| | | | | | |
|---|---|---|---|---|---|
| | មានឈ្មោះគ្រូបង្រៀនមួយចំនួនខុសក្នុងតារាងបៀវត្ស ដូចនេះមិនអាចតម្លើងថ្នាក់បាន | - ការិ.អប់រំពុំបាន ពិនិត្យឯកសារបានត្រឹម ត្រូវមុននឹងដាក់ជូនការិ.ពាក់ព័ន្ធ<br>- ការបំពេញទិន្នន័យនិងឯកសារយោងពុំគ្រប់ជ្រុងជ្រោយ។ | | | |
| ៥ | ការដាក់មន្ត្រីចូលនិវត្តន៍<br>- ពុំបានតម្លើងថ្នាក់ជាកិត្តិយសជូនមន្ត្រី<br>- មានការយឺតយ៉ាវ | - ពុំបានលើកសំណើ មុនពេលចូលនិវត្តន៍<br>- សាមីខ្លួនពុំបានរៀប ចំឯកសារជាមុន (មកដាក់ពេលគាត់ចូលនិវត្តន៍ហើយ) | | - ស្នើការិយាល័យរៀបចំលើក សំណើម្លើងថ្នាក់ជាកិត្តិយស និងលើកសំណើដាក់មន្ត្រីចូលនិវត្តន៍យ៉ាងតិច២ខែមុនពេល ចូលនិវត្តន៍<br>(លេខាធិការដ្ឋានគ.ជ.អ.ប. ស្នើអភិបាលក្រុងស្រុកពិនិត្យជាមួយអ្នកពាក់ព័ន្ធនានាដោះស្រាយបញ្ហានេះ។) | ស្រុកសង្កែ |
| ៦ | ចេញដីកាដាក់មន្ត្រីចូលនិវត្តន៍មិនបាន | មិនមានឈ្មោះក្នុងសមារណកម្មរបស់រដ្ឋបាលស្រុកហើយមន្ទីរអប់រំថាមន្ត្រីនេះបានផ្ទេរឱ្យស្រុកហើយ | គ្រូបង្រៀនម្នាក់នៃបឋមសិក្សាបាឡាត់ ( គង់ សារ៉ាត) | (លេខាធិការដ្ឋានគ.ជ.អ.ប. ស្នើអភិបាលក្រុងស្រុកពិនិត្យជាមួយអ្នកពាក់ព័ន្ធនានាដោះស្រាយបញ្ហានេះ។) | ស្រុកសង្កែ |
| ៧ | ការលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌ<br>- លប់ឈ្មោះដោយទទួលមរណភាពពុំបានទាន់ពេល | ការិយាល័យសាមីពុំបានសម្របសម្រួលជាមួយគ្រួសារសព និងលើកសំណើសុំលុបឈ្មោះមករដ្ឋបាលស្រុកបានទាន់ពេលវេលា | - អង្គភាពគ្រប់គ្រងផ្ទាល់<br>- ការិយាល័យទទួលបន្ទុក | - ស្នើរៀបចំសំបុត្រមរណភាពមន្ត្រី និងឯកសារពាក់ព័ន្ធនឹងមន្ត្រី។<br>-ការិយាល័យត្រូវធ្វើសំណើមក រដ្ឋបាលស្រុកយ៉ាងយូរ២សប្តាហ៍ ក្រោយទទួលមរណភាព។ | ស្រុកសង្កែ |
| ៨ | - ពិបាកក្នុងការរៀបចំតម្លើងថ្នាក់តាមវេន និងតាមកម្រិតសញ្ញាបត្រ ជូនបុគ្គលិកអប់រំ | -ខុសឈ្មោះ ថ្ងៃខែឆ្នាំកំណើតភេទ ក្នុងតារាងបៀវត្ស | មន្ត្រីការិយាល័យ លោកគ្រូអ្នកគ្រូ | -ស្នើសុំការណែនាំពីនីតិវិធីក្នុងការកែសម្រួល | ស្រុកសំឡូត<br>ស្រុករុក្ខគិរិ |

| | | | | | |
|---|---|---|---|---|---|
| | | -ឈ្មោះគ្រូខ្លះខុស ទៅនឹងឯកសារ (សញ្ញាប័ត្រ សំបុត្រកំណើត) | | | |
| ៩ | ខុសអក្ខរាវិរុទ្ធ និងភេទរបស់គ្រូបង្រៀនក្នុងតារាងបៀវត្ស | | ខុសភេទគ្រូបង្រៀនចំនួន ០២រូប និងខុសអក្ខរាវិរុទ្ធគ្រូបង្រៀនចំនួន ០១រូប | លេខាធិការដ្ឋានគ.ជ.អ.ប. ស្នើអភិបាលក្រុងស្រុកពិនិត្យជាមួយអ្នកពាក់ព័ន្ធនានាដោះស្រាយបញ្ហានេះ។ | ស្រុករតនមណ្ឌល<br>ស្រុកគាស់ក្រឡ<br>ស្រុកសំឡូត |
| ១០ | ខ្វះមន្ត្រីជំនាញការងារគ្រប់គ្រងធនធានមនុស្ស និងការងារហិរញ្ញវត្ថុនៅការិ.ធនធានមនុស្ស និងការិ.រដ្ឋបាលហិរញ្ញវត្ថុ ព្រមទាំងមន្ត្រីដែលមានស្រាប់ពុំមានជំនាញទាំងនេះ | | | សំណូមពរមន្ត្រីជួយការងារផ្នែកគ្រប់គ្រងធនធានមនុស្ស ក្នុងការិយាល័យ មានមន្ត្រីយ៉ាងតិច៣ បានអនុវត្តន៍បានល្អ<br>ប្រសើរ<br>គជអបៈ ស្នើអភិបាលស្រុក សម្របសម្រួលការងាររបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅការិ.អប់រំ និងមន្ត្រីនៅការិ.រដ្ឋបាលហិរញ្ញវត្ថុ | ក្រុងបាត់ដំបង<br>ស្រុកបាណន់<br>ស្រុកភ្នំព្រឹក<br>ស្រុកគាស់ក្រឡ<br>ស្រុកមោងឫស្សី<br>ស្រុកសង្កែរ<br>ស្រុកសំពៅលូន<br>ស្រុកសំឡូត<br>ស្រុករុក្ខគិរី<br>ស្រុកឯកភ្នំ |
| ១១ | មន្ត្រីនៅខ្វះសម្ថភាពលើការងារ កំណែទម្រង់ថ្មីៗ | ខ្វះជំនាញសមត្ថភាពនៅមានកម្រិត | ៧០ % នៃមន្ត្រីសរុប | សំណូមពរមានវគ្គកសាងសម្ថភាពបន្ថែមដូចជាវគ្គតាក់តែងលិខិតរដ្ឋបាលអោយសមស្របតាមបរិបទការងារនៅថ្នាក់ក្រោមជាតិដូចសព្វថ្ងៃ(សុំគំរូលិខិតអោយដូចគ្នាទាំងរដ្ឋបាលអប់រំដែលផ្ញើមក និងរដ្ឋបាលស្រុក)<br>គជអបៈ សេចក្តីណែនាំស្តីពីការអនុវត្តមុខងារអប់រំនឹងដាក់ចេញឆាប់ៗ និងកែសម្រួលសេចក្តី | ស្រុកបាណន់ |

| | | | | | |
|---|---|---|---|---|---|
| | | | | ណែនាំនីតិវិធីរដ្ឋបាល ព្រមទាំងមានការបណ្តុះបណ្តាល | |
| ១២ | ពុំអាចផ្លាស់ប្តូរកន្លែងបម្រើការងារទៅក្រៅស្រុក និងក្រៅខេត្ត (ផ្លាស់ប្តូរទៅតាមសហព័ទ្ធ, ទៅជិតផ្ទះ) | ដោយសារលិខិតរបស់ក្រសួងមុខងារសាធារណៈ | | គជអប៖ រង់ចាំការណែនាំថ្មីពីក្រសួងមុខងារសាធារណៈ | ស្រុកភ្នំព្រឹក |
| ១៣ | ពុំទាន់យល់ច្បាស់ពីរបៀបរបបនៃការតែងតាំង ការប្រគល់ភារកិច្ច និងការផ្លាស់ប្តូរកន្លែងធ្វើការងាររបស់មន្ត្រីរាជការ និងបុគ្គលិកអប់រំ | មិនធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាល | | សុំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបុគ្គលិក។<br>គជអប៖ កំពុងកែសម្រួលសេចក្តីណែនាំការគ្រប់គ្រងបុគ្គលិកនៅថ្នាក់ក្រោមជាតិ | ស្រុកភ្នំព្រឹក<br>ស្រុកសំឡូត<br>ស្រុកគាស់ក្រឡ |
| ១៤ | ពុំទាន់មានទម្រង់ថ្មីនៃលិខិតផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក | គ្មានទម្រង់គំរូច្បាស់លាស់ | ការងារនៅអប់រំនិងការងារនៅរដ្ឋបាល ស្រុកមិនស្របគ្នា (លិខិតស្នើសុំឈប់សម្រាក) | សុំមានការណែនាំបណ្តុះបណ្តាល ដល់មន្ត្រីការិ. អប់រំ,ការិ.រដ្ឋបាល និងហិរញ្ញវត្ថុ ,ការិ.គ្រប់គ្រងធនធានមនុស្ស<br>គជអប៖ ថ្នាក់ជាតិកំពុងរៀបចំសេចក្តីណែនាំរដ្ឋបាលថ្មី និងស្នើអភិបាលស្រុកសម្របសម្រួលដោះស្រាយក្នុងពេលអន្តរកាលនេះ | ស្រុកឯកភ្នំ |
| ១៥ | ទំនាក់ទំនងការផ្ទៃក្នុងរវាងការិ.អប់រំ និងការិ.ផ្សេងទៀតពុំទាន់មានភាពរលូន<br>-ចរន្តការងារការិយាល័យអប់រំ យុវជន និងកីឡា (ដែលមានមន្ត្រីច្រើន) ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនិងការិយាល័យគ្រប់គ្រងធនធានមនុស្ស មិនទាន់មានភាពស៊ីចង្វាក់គ្នាបានរលូននៅ ឡើយ។ | ការិយាល័យដែលបានសមាហរណកម្ម មកមិនទាន់បានស្វែង យល់ឲ្យស៊ីជំរៅអំពីលក្ខខ័ណ្ឌ និងការអនុវត្តការងារ តួនាទី ភារកិច្ចក្រោយពីការធ្វើសមាហរណកម្មរួច។ ជាពិសេស លំហូការងារ បែបបទ របៀបរបប និងឯកសារនានា ពាក់ព័ន្ធការងាររដ្ឋបាលស្រុក | | ស្នើសុំបើកវគ្គបណ្តុះបណ្តាល និងមានការណែនាំលំអិត អំពីបែបបទ នីតិវិធី របៀបរបបការងារជាពីសេសការធ្វើលិខិត និងការប្រើប្រាស់ លិខិតរដ្ឋបាលរបស់ ស្រុក ដោយកំណត់អំពីទម្រង់ជាក់លាក់<br>គជអប៖ ថ្នាក់ជាតិកំពុងរៀបចំសេចក្តីណែនាំរដ្ឋបាលថ្មី និងស្នើអភិបាលស្រុកសម្របសម្រួលដោះស្រាយក្នុងពេលអន្តរកាលនេះ | ស្រុកឯកភ្នំ<br>ស្រុកកំរៀង |

| ការគ្រប់គ្រងហិរញ្ញវត្ថុ | | | | | |
|---|---|---|---|---|---|
| ១៦ | ខ្វះថវិកាលំហែមាតុភាពគ្រូបង្រៀន | គ្រោងថវិការប្រចាំឆ្នាំពុំគ្រប់គ្រាន់ | ៣៥,០០០,០០០ រៀល | ស្នើសុំបន្ថែមឥណទាន ឬនិយ័ត | ស្រុកមោងឬស្សី |
| ១៧ | ពុំមានថវិកាគ្រប់គ្រាន់សម្រាប់ឧបត្ថម្ភលើការលំហែមាតុភាព | ធ្វើសំណើសុំមិនបាន | ២៥នាក់ | ធ្វើនិយ័ត្នភាពថវិកា | ស្រុកកំរៀង |
| ១៨ | ខ្វះថវិកាឧបត្ថម្ភបុណ្យចូលឆ្នាំ និងភ្ជុំបិណ្ឌ | ពុំបានគ្រោងថវិកា | ៦៦,៣០០,០០០ រៀល | ស្នើសុំបន្ថែមឥណទាន ឬនិយ័ត | ស្រុកមោងឬស្សី |
| ១៩ | ខ្វះថវិកាលើកទឹកចិត្តមជ្ឈមណ្ឌលសិក្សាហគមន៍ចំនួន ១០ នាក់ | ពុំបានគ្រោងថវិកា | ៦,០០០,០០០ រៀល | ស្នើសុំបន្ថែមឥណទាន ឬនិយ័ត | ស្រុកមោងឬស្សី |
| ២០ | ខ្វះថវិកានិវត្តជន | គ្រោងថវិការប្រចាំឆ្នាំពុំគ្រប់គ្រាន់ | ៩,០០០,០០០ រៀល | ស្នើសុំបន្ថែមឥណទាន ឬនិយ័ត | ស្រុកមោងឬស្សី |
| ២១ | កញ្ចប់ថវិកាសម្រាប់ចំណាយក្នុងខ្ទង់មួយចំនួន មានការខ្វះខាតច្រើន។ | ស្រុកទទួលតួលេខដែលមានស្រាប់ ក្នុងសៀវភៅថវិកា។ | ឧទាហរណ៍ អនុគណនីលេខ ៦៤០៥២ទឹកប្រាក់អ្នកសម្រាល កូនមានសម្រាប់តែស្ត្រី៤នាក់ ប៉ុន្តែជាក់ស្តែង គិតត្រឹមខែសីហា ស្ត្រីសម្រាលកូនសរុបចំនួន៣៥ នាក់ និងអាចមានច្រើនលើសពី នេះ បើគិតដល់ចុងឆ្នាំ ដូច្នេះទឹកប្រាក់នេះមានការខ្វះខាតច្រើន។ | គជអបះ និយ័ត្នកម្ម ឬស្នើសុំឥណទានបន្ថែម | ស្រុកសង្កែ |
| ២២ | មានភាពស្រពិចស្រពិលចំពោះនីតិវិធីចាយវាយលើចំណាយមួយចំនួន។ (មន្ត្រីការិ.ហិរញ្ញវត្ថុស្រុក) | ដោយសារមិនមានវគ្គបណ្តុះបណ្តាល ចំពោះចំណាយលើវិស័យអប់រំនេះ ធ្លាប់មានចំណាយលើអ្វីខ្លះ? ហើយ | ឧទាហរណ៍ ការចាយវាយលើកិច្ចដំណើរការ សាលារៀនទៅលើអនុគណនី នីមួយៗ។ | - សូមឲ្យមានវគ្គបណ្តុះបណ្តាល អំពីនីតិវិធីលើការចាយវាយអនុ គណនីនីមួយៗ និងតម្រូវការឯកសារភ្ជាប់ត្រូវមានអ្វីខ្លះ? ដើម្បីអាចទូរទាត់បាន។ | ស្រុកសង្កែរ |

| | | | | | |
|---|---|---|---|---|---|
| | | ការ ទូទាត់ត្រូវមានឯកសារភ្ជាប់អ្វីខ្លះ? | | | |
| ២៣ | ការិ.អប់រំតែងទាមទារឲ្យមានការទូទាត់ភ្លាមៗ និងឆាប់រហ័ស តែហិរញ្ញវត្ថុស្រុកទូទាត់ជូនយឺតជាងការចង់បានរបស់ការិ.អប់រំ | ព្រោះការិ.ហិរញ្ញវត្ថុស្រុកត្រូវទូទាត់តាម នីតិវិធីហិរញ្ញវត្ថុ | | គជអបៈ ស្នើការិរដ្ឋបាលហិរញ្ញវត្ថុពន្លឿនការទូទាត់ និងពិនិត្យនីតិវិធីការប្រើប្រាស់ថវិការបស់ការ.អប់រំ | ស្រុកសង្កែរ |
| ២៤ | នីតិវិធីទូទាត់ថវិកាស្មុគស្មាញ | ថវិកាធ្លាក់យឺត | តាមគោលការណ៍កំណត់ | រទ្យទ័យបុរេប្រទាន | ស្រុកបវេល |
| ២៥ | ការិ.អប់រំពុំមានសាច់ប្រាក់រដ្ឋទេយ្យបុរេប្រទានសម្រាប់ទិញសម្ភារៈដោយខ្លួនឯង។ ដោយសារមិនទទួលបានរទ្យទ័យបុរេប្រទាន១០០%<br>កិច្ចលទ្ធកម្មៈ ការិ.អប់រំយល់ថាជាការផ្តល់ថវិកាបន្ថែមលើរទ្យទ័យបុរេប្រទានក្រោយកិច្ចលទ្ធកម្ម | រងចាំពេលយូរ មិនទទួលបានថវិកាពេញលេញ | តាមគោលការណ៍កំណត់ | រទ្យទ័យបុរេប្រទាន<br>គជអបៈ ការិ.អប់រំត្រូវអនុវត្តតាមនីតិវិធីអនុវត្តថវិកាក្រុង ស្រុក ឬថ្នាក់ជាតិនឹងពិនិត្យមើលឡើងវិញការប្រើប្រាស់កញ្ចប់ថវិកាអប់រំ | ស្រុកបវេល |
| ២៦ | ខ្វះថវិកាបៀវត្សមូលដ្ឋាន | គ្រោងថវិកាប្រចាំឆ្នាំពុំគ្រប់គ្រាន់ | ២៦,២២០,០០០រៀល | សំណូមពរទម្លាក់ថវិកាអោយបានច្រើនជាង ៣០ លាន សំរាប់ចំណាយលើការងាររដ្ឋបាល | ស្រុករតនមណ្ឌល |
| ២៧ | ខ្វះថវិកាសម្រាប់គ្រូចូលនិវត្តន៍ | | ៦,៤២០,០០០ រៀល | | ស្រុករតនមណ្ឌល |
| ២៨ | ខ្វះថវិកាឧបត្ថម្ភបុណ្យភ្ជុំ និងចូលឆ្នាំខ្មែរ | | ១,១០០,០០០ រៀល | | ស្រុករតនមណ្ឌល |
| ២៩ | ខ្វះសម្ភារឧបករណ៍បច្ចេកទេស និងគ្រឿងសង្ហារឹម | | Computer, Printer, Photocopy | | ស្រុករតនមណ្ឌល |
| ៣០ | មិនទាន់យល់ច្បាស់ពីការងារថ្មីៗ (ដូចខាងលើ) | ខ្វះឯកសារលិខិតបទដ្ឋានគតិយុត្តិ<br>ទាក់ទង និងការផ្ទេរមុខងារទាំងបី | -ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ<br>-ការិយាល័យអប់រំ | ស្នើសុំមានវគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ | ស្រុកបាណន់ |

| | | | | | |
|---|---|---|---|---|---|
| ៣១ | ចរិកាដំណើរការការិយាល័យអប់រំ យុវជន និងកីឡាមានភាពយឺតយ៉ាវ | ការទូទាត់តាមកិច្ចលទ្ធកម្ម | | ស្នើអនុវត្តចរិកាតាមការទូទាត់ត្រង់ រឺតាមការធ្វើបុរេប្រទាន | ស្រុកភ្នំព្រឹក |
| ៣២ | គ្មានរបបប្រេងឥន្ទនៈសម្រាប់ប្រើប្រាស់នៅការិយាល័យអប់រំ យុវជន និងកីឡា | គ្មានកញ្ចប់ចរិកាចំណាយលើប្រេងឥន្ទនៈ | | ស្នើសុំផ្តលើរបបប្រេងឥន្ទនៈសម្រាប់ប្រើប្រាស់ | ស្រុកភ្នំព្រឹក |
| ៣៣ | ចរិកាដំណើរការសាលាបឋមសិក្សា និងមត្តេយ្យសិក្សាមានភាពយឺតយ៉ាវ | មិនមានការណែនាំ រឺគ្មានវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់ហិរញ្ញវត្ថុ | | ស្នើសុំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការប្រើប្រាស់ហិរញ្ញវត្ថុ | ស្រុកភ្នំព្រឹក |
| ៣៤ | ចរិកាធ្វើលទ្ធកម្ម | មានការដេញថ្លៃ និងកាត់ពន្ធ | -កាត់ពន្ធ១១.០១%នៃចរិកាលទ្ធកម្ម | -ស្នើសុំ (កញ្ចប់ចរិការរបស់ការិ.អប់រំ សូមកុំធ្វើលទ្ធកម្ម)<br>គជអបៈ ថ្នាក់ជាតិនឹងពិនិត្យមើលឡើងវិញការប្រើប្រាស់កញ្ចប់ចរិកាអប់រំ | ស្រុកថ្មគោល |
| ៣៥ | ខ្វះមន្ត្រីជួយការងារហិរញ្ញវត្ថុ | | | ស្នើសុំមន្ត្រីក្របខណ្ឌឬមន្ត្រីកិច្ច សន្យាបន្ថែម | ស្រុកសំឡូត |
| ៣៦ | -ខ្វះប្រាក់បេសកកម្មរបស់មន្ត្រីការិយាល័យអប់រំសម្រាប់ចំណាយចេញទៅក្រៅស្រុក ក្រៅខេត្ត | -កញ្ចប់ចរិការបស់រដ្ឋបាលស្រុកមិនមានគ្រប់គ្រាន់ | -ចំនួនមន្ត្រីការិយាល័យអប់រំ ១២ នាក់ | -ស្នើសុំប្រាក់ឧបត្ថម្ភបេសកកម្មមន្ត្រីការិយាល័យអប់រំ សម្រាប់ក្រៅស្រុក និងខេត្ត<br>គជអបៈ ថ្នាក់ជាតិនឹងពិនិត្យមើលដោយ ប្រើប្រាស់កញ្ចប់ចរិការបស់ការិ.អប់រំ ឬកញ្ចប់ចរិកាផ្ទាល់របស់ក្រុង ស្រុក | ស្រុកសំឡូត |
| ៣៧ | នីតិវិធីហិរញ្ញវត្ថុមានភាពស្មុគស្មាញ និងការអនុវត្តមានភាពយឺតយ៉ាវខ្លះ | ការងារថ្មី នីតិវិធីថ្មី ទាមទាចំណេះដឹង និងសមត្ថភាព | -ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ<br>-ការិយាល័យអប់រំ | ស្នើសុំមានវគ្គបណ្តុះបណ្តាល ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ | ស្រុករុក្ខគិរី |
| ៣៨ | មិនទាន់បានទូទាត់ចរិកាបេសកកម្មស្រុក | និតិវិធីស្មុកស្មាញ(មន្ត្រីជំនាញខ្វះបទពីសោធន៍ | ១៨,០០០,០០០រៀល | សូមបញ្ចូលចរិកាទៅក្នុងគណនីរបស់ការិយាល័យអប់រំស្រុក(ទូទាត់ជាចរិកាបុរេប្រទាន | ស្រុកកំរៀង |

| | | | | | |
|---|---|---|---|---|---|
| ៣៩ | ថវិកាដំណើរការការិយាល័យ អនុគណនី ៦០០២១ | ហិរញ្ញវត្ថុរដ្ឋបាលស្រុក ធ្វើលទ្ធកម្មទិញសម្ភារៈ | 5,450,000រៀល | សុំផ្តល់ថវិកាជា ៤ ត្រីមាស ដល់ការិយាល័យអប់រំ ដូចឆ្នាំ មុនសមាហរណកម្ម<br>គជអបៈ ថ្នាក់ជាតិនឹងពិនិត្យមើលឡើងវិញការប្រើប្រាស់កញ្ចប់ថវិកាអប់រំ | ស្រុកឯកភ្នំ |
| ៤០ | មិនទាន់យល់ពីនិតិវិធីគណនាប្រាក់ឧបត្ថម្ភគ្រូជាប់កិច្ចសន្យាគ្រូអប់រំក្រៅប្រព័ន្ធនិងប្រាក់ថ្ងៃព្រហស្បតិ៍ | មិនទាន់មានការបណ្តុះបណ្តាលណែនាំច្បាស់លាស់ | | -មានការណែនាំ និងកំណត់ទឹកប្រាក់ឲ្យបានច្បាស់លាស់ | ស្រុកឯកភ្នំ |
| ៤១ | មិនទាន់យល់ច្បាស់ពីការទូទាត់ថវិកាសាលារៀន | មិនដែលមានវគ្គបណ្តុះបណ្តាលកន្លងមក | | -មានវគ្គបណ្តុះបណ្តាល | ស្រុកឯកភ្នំ |
| **ការគ្រប់គ្រងទ្រព្យសម្បត្តិ និងសម្ភារ** | | | | | |
| ៤២ | ទ្រព្យសម្បត្តិ និងសម្ភារៈ ការិយាល័យអប់រំ និងសាលារៀន ពុំទាន់បានផ្ទេរចូលជា ទ្រព្យសម្បត្តិ និងសម្ភារៈរបស់រដ្ឋបាលក្រុង | ពុំទាន់ទទួលបានសេចក្តីណែនាំ ជាក់លាក់ | មានការិយាល័យអប់រំចំនួន ០១ គ្រឹះស្ថានបឋមសិក្សាចំនួន៣៤ និងគ្រឹះស្ថានមត្តេយ្យសិក្សាចំនួន០៣ | ស្នើសុំសេចក្តីណែនាំ និងនីតិវិធីក្នុងការផ្ទេរទ្រព្យសម្បត្តិឱ្យបាន ជាក់លាក់ | ក្រុងបាត់ដំបង<br>ស្រុកមោងឫស្សី<br>ស្រុករតនៈមណ្ឌល<br>ស្រុកសំពៅលូន<br>ស្រុកសំពៅលូន<br>ស្រុករុក្ខគិរី |
| ៤៣ | សាលាបឋមសិក្សាមួយចំនួនមានភាពទ្រុឌទ្រោមខ្លាំង | ខ្វះបន្ទប់រៀន | សាលាបឋមសិក្សាពិទូគីឡូ ៣៨ មានអគារសិក្សា ១ខ្នង ៥បន្ទប់ បានស្រុតប្រេះស្រាំយ៉ាងខ្លាំង<br>សាលាបឋមសិក្សាអ៊ិនស៊ីដារ៉េដំបូលពុកផុយ និងសាបស្រុត | ស្នើសុំ ជួសជុល និងសាងសង់អគារសិក្សាបន្ថែម<br>គជអបៈ ស្នើរដ្ឋបាលក្រុង ស្រុកលើកសំណើទៅក្រសួង/មន្ទីរអប់រំលើការសាងសង់ និងជួសជុលធំ | ស្រុករតនៈមណ្ឌលស្រុកកំរៀង |
| ៤៤ | ខ្វះខាតសម្ភារ(កុំព្យូទ័រ ព្រីនធ័រ តុ ទូដាក់ ឯកសារ កៅអី) | មិនមានថវិកាសម្រាប់ចំណាយ | កុំព្យូទ័រ៣ ព្រីនធ័រ៣ តុ៤ កៅអី១៥ | ស្នើសុំផ្តល់សម្ភារ | ស្រុកភ្នំព្រឹក |

| | | | | | |
|---|---|---|---|---|---|
| | | | ទូដាក់ឯកសារ២ | គជអបៈ រដ្ឋបាលក្រុង ស្រុកសម្របសម្រួល ដោះស្រាយ និងថ្នាក់ជាតិពិនិត្យផ្តល់ថវិកាបន្ថែមដល់ក្រុង ស្រុក | |
| ៤៥ | អគារការិយាល័យអប់រំ យុវជន និង កីឡាចាស់ | យូរឆ្នាំ ធ្លុះដំបូល ទ្វាខូច | ១ | គជអបៈ រដ្ឋបាលក្រុង ស្រុកសម្របសម្រួល ដោះស្រាយ និងថ្នាក់ជាតិពិនិត្យផ្តល់ថវិកាបន្ថែមដល់ក្រុង ស្រុក | ស្រុកភ្នំព្រឹក |
| ៤៦ | បាក់បែក និងបាត់បង់សម្ភារៈ(សម្ភារតុ កៅអី ក្តាខៀន និងសម្ភារៈមួយចំនួន (ដូចខាងលើ ផ្ទេរ) | សាលាជាប់ធ្វើមណ្ឌលចត្តាឡីស័ក | ៦សាលា | សុំដំណើការសាលារៀនឡើងវិញ | ស្រុកកំរៀង |
| **ការងាររដ្ឋបាល(របៀបរបបការងារ)** | | | | | |
| ៤៧ | កិច្ចការងាររដ្ឋបាលមួយចំនួនមិនទាន់រលូន (លិខិតស្នាម និងត្រា)<br>សម្គាល់៖ ស្រុកហាក់នៅស្ទាក់ស្ទើក្នុងការ អនុញ្ញាតឱ្យការិ.អប់រំប្រើប្រាស់ត្រារបស់ខ្លួនសម្រាប់ទំនាក់ទំនងផ្ទៃក្នុងជាមួយសាលារៀន និងការិ.ពាក់ព័ន្ធនានា។<br>សម្គាល់៖ គ្រូបង្រៀន សុំច្បាប់ឈប់សម្រាកលំហែមាតុភាព និងច្បាប់ដែលមានរយៈពេលវែងត្រង់ទៅការិ.រដ្ឋបាល ដោយពុំបានឆ្លងការិ.អប់រំ | រដ្ឋបាលទូទៅ មិនដូចរដ្ឋបាលជំនាញ | | ស្នើសុំឱ្យមានលិខិតណែនាំ និងវគ្គបណ្តុះបណ្តាល<br>គជអបៈ នឹងដាក់ចេញសេចក្តីណែនាំអំពីនីតិវិធីរដ្ឋបាលថ្មី | ក្រុងបាត់ដំបង |
| ៤៨ | ការងាររបស់ការិ.អប់រំ.ធ្វើតាមគន្លងចាស់ (ពាក់ព័ន្ធនឹងការរៀបចំលិខិតផ្សេងៗ) | មិនទាន់យល់ច្បាស់ពីរបៀបរបការងារថ្មី | | ស្នើសុំការផ្សព្វផ្សាយនិងធ្វើការណែនាំអំពីតួនាទីភារកិច្ចដល់ការិ.ជំនាញ | ស្រុកមោងឫស្សី |

| | | | | | |
|---|---|---|---|---|---|
| ៤៩ | ចរន្តការងារមិនទាន់បានល្អ | ការងារថ្មីមានភាពស្មុគស្មាញច្រើន | រដ្ឋបាលស្រុក ការិ.អប់រំ | ស្នើសុំមានវគ្គបណ្តុះបណ្តាល | ស្រុកសង្កែ |
| ៥០ | កិច្ចការងាររដ្ឋបាលមួយចំនួនពុំទាន់មានភាពរលូត | | | ស្នើសុំបើកវគ្គបណ្តុះបណ្តាល | ស្រុករតនមណ្ឌល |
| ៥១ | លិខិតរដ្ឋបាលនៅមិនទាន់សមស្របតាមការណែនាំនានា | សមត្ថភាពមន្ត្រី | ការិយាល័យអប់រំ | | ស្រុកបាណន់ |
| ៥២ | ទម្រង់រដ្ឋបាលមិនឯកភាព | -មិនមានការណែនាំ | | -ស្នើសុំការណែនាំបន្ថែម | ស្រុកសំពៅលូន |
| ៥៣ | កិច្ចការងាររដ្ឋបាលមួយចំនួនមិនច្បាស់លាស់ | លិខិតមួយចំនួនមិនឆ្លងការិ.អប់រំ | ពាក្យស្នើសុំលំហែរមាតុភាព លិខិតជានាអះអាងរបស់ប្រធានអង្គភាព ពាក្យសុំច្បាប់ឈប់សម្រាក (គ្រូមធ្យម) | ស្នើសុំឱ្យមានលិខិតណែនាំ និងវគ្គបណ្តុះបណ្តាល | ស្រុកថ្មគោល |
| ៥៤ | ការងាររដ្ឋបាលមួយចំនួនមិនទាន់រលូន | ពុំមានមន្ត្រីគ្រប់គ្រាន់ | មន្ត្រីចំនួន០២នាក់ | ស្នើសុំមន្ត្រីក្របខណ្ឌឬកិច្ចសន្យា បន្ថែម | ស្រុកសំឡូត |
| ៥៥ | ចំពោះការអនុវត្តការងាររដ្ឋបាលនៅពុំទាន់បានត្រឹមត្រូវស្របតាមសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលនៅឡើយ | នៅតែបន្តការអនុវត្ត ការងារទម្រង់ចាស់ពីមុន | | ស្នើសុំឱ្យមានលិខិតណែនាំ និងវគ្គបណ្តុះបណ្តាលដល់ ការិយាល័យ | ស្រុករុក្ខគិរី |
| ៥៦ | របៀបរបបការងារមួយចំនួន ធ្វើតាមទម្លាប់ពីមុន នៅមិនទាន់សម្របតាមការណែនាំ ឬការផ្ទេមុខងារនៅឡើយ | នៅបែងចែក គោលការណ៍ក្រសួងអប់រំដោយឡែក ក្រសួងមហាផ្ទៃដោយឡែក | ការិយាល័យអប់រំ | ផ្សព្វផ្សាយសេចក្តីណែនាំបន្ថែមដល់លោកគ្រូ អ្នកគ្រូ និងការិ.អបរំ | ស្រុករុក្ខគិរី |
| ៥៧ | កិច្ចការងាររដ្ឋបាលមួយចំនួនមិនទាន់រលូន | រដ្ឋបាលទូទៅ មិនដូចរដ្ឋបាលជំនាញ | | ស្នើសុំឱ្យមានលិខិតណែនាំ និងវគ្គបណ្តុះបណ្តាល | ស្រុកគាស់ក្រឡ |
| ៥៨ | ការតាក់តែងឯកសារ | ទម្រង់បែបបទឯកសារ | ឯកសាររបាយការណ៍ សមទ្ធិកម្ម | មានវគ្គបណ្តុះបណ្តាល | ស្រុកកំរៀង |

| | | | | | |
|---|---|---|---|---|---|
| | | | របាយការសុំណើសុំថវិកាផ្សេងៗ | គជអបះ នឹងដាក់ចេញសេចក្តីណែនាំអំពីនីតិវិធីរដ្ឋបាលថ្មី | |
| **ទំនាក់ទំនងការងារ** | | | | | |
| ៥៩ | ទំនាក់ការងារមានភាពល្អ | | | | ស្រុកមោងឫស្សី |
| ៦០ | មន្ត្រីបច្ចេកទេសពុំទាន់យល់ច្បាស់ពីនីតិវិធីការងារថ្មីក្រោយសមាហរណកម្ម | | - | - ស្នើសុំមានវគ្គបណ្តុះបណ្តាល ស្តីពីមុខងារដែលបានផ្ទេរបញ្ចូលមកក្រោមរចនាសម្ព័ន្ធរដ្ឋបាល ស្រុក | ស្រុកសង្កែ |
| ៦១ | រដ្ឋបាលស្រុកពិបាកគ្រប់គ្រងវត្តមាន | ទីតាំងនៅឆ្ងាយគ្នា | ការិយាល័យ | | ស្រុកបាណន់ |
| ៦២ | ការអនុវត្តកិច្ចការមួយចំនួន សម្រេចត្រឹម ថ្នាក់ការិយាល័យដោយខ្លួនឯងដោយពុំ សុំយោបល់ពីក្រុមប្រឹក្សា ឬគណៈអភិបាល ឡើយ | ការិយាល័យអប់រំគិតថាជាការងារ<br>ជំនាញបច្ចេកទេស | | រៀបចំវគ្គបណ្តុះបណ្តាល អំពីតួនាទីភារកិច្ចនិងទំនាក់ទំនងរបៀបរបបការងារ | ស្រុករុក្ខគិរី |
| **ផ្សេងៗ** | | | | | |
| ៦៣ | អគារការិយាល័យអប់រំតូច និងចាស់ | កន្លែងតូចចង្អៀត ចាស់ទ្រុឌទ្រោម | ៣អាគារ<br>មាន១បន្ទប់អង្គុយធ្វើការរួមគ្នាទាំង ១០រូប | ស្នើសុំសាងសង់អាគារ៣បន្ថែម | ស្រុកភ្នំព្រឹក<br>ស្រុកសំពៅលូន<br>ស្រុករុក្ខគិរី<br>ស្រុកកំរៀង<br>ស្រុករតនមណ្ឌល |
| ៦៤ | ស្នើសុំវគ្គបណ្តុះបណ្តាល --ស្នើតែគ្រប់ក្រុងស្រុកទាំង១៤ | | | | |

## ឧបសម្ព័ន្ធទី៤៖ សង្ខេបសេចក្ដីនៃការស្វែងយល់ពីតម្រូវការសិក្សា

### សារតា

ខេត្តបាត់ដំបងគឺជាខេត្តដំបូងគេបង្អស់ក្នុងចំណោមរាជធានីខេត្តទាំង២៥ ដែលរាជរដ្ឋាភិបាលកម្ពុជា បានប្រគល់មុខងារដល់រដ្ឋបាលក្រុង/ស្រុកទាំង១៤របស់ខ្លួនដើម្បីអនុវត្តលើវិស័យអប់រំរួមមាន ការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងការអប់រំបឋមសិក្សា និងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។ តាមរយៈអនុក្រឹត្យលេខ ១៨២និង១៨៤ ក្រៅពីមុខងារដែលបានប្រគល់ខាងលើ ការិយាល័យអប់រំ យុវជន និងកីឡា(អ.យ.ក.)ក្រុង/ស្រុក ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យដោយផ្ទាល់ពីរដ្ឋបាលក្រុង/ស្រុកនៃខេត្តបាត់ដំបង។

ដើម្បីស្វែងរកថាតើមានតម្រូវការចំណេះដឹងបច្ចេកទេស និងជំនាញចាំបាច់អ្វីខ្លះទាក់ទងនឹងផ្នែកអប់រំក្នុងការអនុវត្តមុខងារដែលបានប្រគល់ប្រកបដោយជោគជ័យនិងមានប្រសិទ្ធិភាព ការវាយតម្លៃពីតម្រូវការបណ្តុះបណ្តាលជាមួយរដ្ឋបាលក្រុង/ស្រុកនៅខេត្តបាត់ដំបង ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១។ លទ្ធផលដែលកើតចេញពីការវិភាគនេះនឹងជួយដល់មន្ទីរ អ.យ.ក. ខេត្តបាត់ដំបង ក្នុងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពដើម្បីគាំទ្រដល់រដ្ឋបាលក្រុង/ស្រុកនៅពេលចាំបាច់ណាមួយ។

### លទ្ធផលរកឃើញសំខាន់ៗ

ជាមួយនឹងអត្រាឆ្លើយតបពីការស្ទង់មតិចំនួន៦៨% លទ្ធផលវិភាគបង្ហាញពីការរកឃើញសំខាន់ៗដូចខាងក្រោម៖

*ផ្នែកប្រជាសាស្ត្រ*

- ការស្ទង់មតិនេះមានមន្ត្រីដែលបានឆ្លើយតបចំនួន ២៨៦នាក់ ក្នុងនោះមាន២២៣នាក់ (៧៨%) មកពីរដ្ឋបាលក្រុង/ស្រុក ៥៥នាក់ (១៩%) មកពីការិយាល័យ អ.យ.ក. ក្រុង/ស្រុក និង ៨នាក់ (៣%) សុំមិនបញ្ជាក់ពីទីកន្លែងការងារ/តួនាទី ។
- ក្នុងចំណោម ២២៣នាក់ មកពីរដ្ឋបាលក្រុង/ស្រុក មានបុរសចំនួន ១៦២នាក់ (៧៣%) ស្ត្រីចំនួន៥១នាក់ (២៣%) ហើយអ្នកសុំមិនប្រាប់ពីភេទប្រុស ឬស្រី មានចំនួន ១០នាក់ (៤%)។

- ក្នុងចំណោម៥៥នាក់ មកពីការិយាល័យ អ.យ.ក. ក្រុង/ស្រុក មានបុរស ៤០នាក់ (៧៣%) ស្ត្រី ៩នាក់ (១៦%) និងអ្នកសុំមិនប្រាប់អំពីភេទប្រុស ឬស្រី មាន ៦នាក់ (១១%)។

*<u>ប្រធានបទបណ្តុះបណ្តាល</u>*

ប្រធានបទបណ្តុះបណ្តាលត្រូវបានបែងចែកជា ៣ប្រភេទធំៗគឺ ចំណេះដឹងបច្ចេកទេស (១០ប្រធានបទ) ចំណេះដឹងបច្ចេកវិទ្យា (៥ប្រធានបទ) និងការអភិវឌ្ឍផ្ទាល់ខ្លួន (៧ប្រធានបទ)។ ប្រធានបទនៃការគ្រប់គ្រងបុគ្គលិកអប់រំត្រូវបានចាត់ថ្នាក់ជាអាទិភាពសម្រាប់ចំណេះដឹងបច្ចេកទេស ក៏ដូចជាជំនាញកុំព្យូទ័រ និងភាពជាអ្នកដឹកនាំមូលដ្ឋានសម្រាប់ចំណេះដឹងជាបន្តបន្ទាប់។

*<u>ឧបសគ្គចំពោះការបណ្តុះបណ្តាល</u>*

អ្នកចូលរួមក៏ត្រូវបានស្នើសុំឱ្យកំណត់នូវឧបសគ្គដែលរារាំងក្នុងការចូលរួមការបណ្តុះបណ្តាលនានានៅពេលអនាគត លើខ្នាតលីគ័រ (Linkert scale) ប្រសិនបើពួកគេយល់ស្របទាំងស្រុង យល់ស្រប មិនយល់ស្រប ឬមិនយល់ស្របទាំងស្រុង ទៅនឹងពំនោលចំនួន៨។

*<u>ទំនាក់ទំនងគ្នារវាងកិច្ចពិភាក្សាក្រុមគោលដៅ និងការពិភាក្សាទៅលើការរកឃើញ</u>*

ចំណុចដែលបានរកឃើញក្នុងកំឡុងពេលពិភាក្សាជាមួយក្រុមគោលដៅ មានទំនាក់ទំនងទៅនឹងលទ្ធផលស្ទង់មតិ ហើយត្រូវបានយកមកពិភាក្សា និងដាក់ជាក្រុមតាមប្រធានបទដូចខាងក្រោមៈ

*យន្តការគាំទ្រ និងធនធាន*

អ្នកចូលរួមបានត្អូញត្អែរអំពីកង្វះការគាំទ្រជាប្រព័ន្ធពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។ បញ្ហានេះវារឹតតែពិបាកបន្ថែមទៀតជាមួយនឹងកង្វះធនធាន (បុគ្គលិក ហិរញ្ញវត្ថុ និងសម្ភារ) នៅរដ្ឋបាលមូលដ្ឋាន។

*ភាពមិនប្រាកដប្រជា*

នីតិវិធីប្រតិបត្តិការ និងការអនុវត្តការងារនៅមានភាពមិនច្បាស់លាស់បង្កើតឱ្យមានការភ័ន្តច្រលំខ្លះៗទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវលើការងារក្នុងចំណោមបុគ្គលិកនៅរដ្ឋបាលក្រុង/ស្រុក និងការិយាល័យ អ.យ.ក. ក្រុង/ស្រុក មួយចំនួន

*ទំនាក់ទំនង*

ទំនាក់ទំនងផ្ទាល់ខ្លួនត្រូវបានរកឃើញថាមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហារដ្ឋបាលនានា ដែលរដ្ឋបាលក្រុង/ស្រុក និងការិយាល័យ អ.យ.ក. ក្រុង/ស្រុកកំពុងប្រឈម។ នៅក្រុង/ស្រុកណាដែលប្រធានការិយាល័យ អ.យ.ក. ក្រុង/ស្រុកមានទំនាក់ទំនងល្អជាមួយនឹងរដ្ឋបាលក្រុង/ស្រុក អ្នកចូលរួមបានបង្ហាញអំពីការមិនពេញចិត្តបន្តិចបន្តួចប៉ុណ្ណោះ ហើយការអនុវត្តការងារអាចប្រព្រឹត្តទៅបានដោយរលូនដោយមានការសម្របសម្រួលគ្នាច្រើន។

*ការលើកទឹកចិត្ត*

ទោះបីជាមានបញ្ហាប្រឈមនានាដូចបានលើកឡើងក៏ដោយ ការលើកទឹកចិត្តក្នុងការរៀនសូត្រ និងសម្របខ្លួនទៅនឹងដំណើរការនៃការងារថ្មីត្រូវបានរកឃើញ។ អ្នកចូលរួមកំពុងរង់ចាំការណែនាំបន្ថែមឱ្យកាន់តែច្បាស់លាស់ និងការគាំទ្រពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។

## សន្និដ្ឋាន និងអនុសាសន៍

អនុសាសន៍ខាងក្រោមអាចនឹងមិនគ្របដណ្តប់នូវអ្វីៗទាំងអស់ ដែលបានរកឃើញពីការសិក្សាស្រាវជ្រាវនេះ។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគនៃការស្ទង់មតិ និងការពិភាក្សាជាមួយក្រុមគោលដៅ អាចទាញជាការសន្និដ្ឋាន និងអនុសាសន៍ដូចខាងក្រោម៖

- យន្តការគាំទ្រដែលអាចផ្តល់នូវគោលការណ៍ណែនាំច្បាស់លាស់អំពីនីតិវិធីរដ្ឋបាលនិងបច្ចេកទេសមួយចំនួនគឺចាំបាច់ត្រូវរៀបចំឡើង។ ជាឧទាហរណ៍ កិច្ចការនេះអាចសម្រេចទៅបានតាមរយៈការបង្កើតក្រុមការងារគ្រប់គ្រង/អនុវត្តមុខងារអប់រំ ទាំងនៅរដ្ឋបាលក្រុង/ស្រុកនិងមន្ទីរ អ.យ.ក. ។
- វិធីសាស្រ្តជាយុទ្ធសាស្រ្តក្នុងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលក្រុង/ស្រុក និងការិយាល័យអ.យ.ក. ក្រុង/ស្រុកគួរចាំបាច់ត្រូវបានគ្រោងឡើង។ នេះតម្រូវឱ្យមានការបែងចែកថវិកាត្រឹមត្រូវ និងការរៀបចំកម្មវិធីបណ្តុះបណ្តាលអោយបានទៀងទាត់។ មន្ទីរ អ.យ.ក. អាចដើរតួជាអ្នកនាំមុខក្នុងការបង្កើតឯកសារក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា។
- ចំណេះដឹង និងជំនាញពាក់ព័ន្ធដែលតបានបណ្តុះបណ្តាលពីមុន ត្រូវការការកែលម្អ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

- បុគ្គលិកនៅតាមរដ្ឋបាលក្រុង/ស្រុកភាគច្រើន មានបទពិសោធន៍ការងារតិចជាង ០២ឆ្នាំ ក្នុងមុខតំណែង។ ដូច្នេះពួកគេត្រូវការពេលវេលាបន្ថែម និងការគាំទ្រសមស្របដើម្បីបំពេញកាតព្វកិច្ចប្រកបដោយប្រសិទ្ធភាព។
- រដ្ឋបាលក្រុង/ស្រុកត្រូវការសមត្ថភាពបន្ថែមដើម្បីគ្រប់គ្រងមុខងារអប់រំ។ ការគ្រប់គ្រងបុគ្គលិកអប់រំគឺជាជំនាញដែលមានអាទិភាព បន្ថែមលើជំនាញបណ្តុះបណ្តាលអំពីមូលដ្ឋានកុំព្យូទ័រ។
- ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងពេលវេលា និងជំនាញទំនាក់ទំនងគឺជាផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងសម្រាប់ទាំង រដ្ឋបាលក្រុង/ស្រុក និងការិយាល័យ អ.យ.ក. ក្រុង/ស្រុក។ ទាំងនេះមានសារៈសំខាន់ក្នុងការអនុវត្តមុខងារប្រកបដោយប្រសិទ្ធភាពក្នុងលក្ខណៈសហប្រតិបត្តិការ និងសម្របសម្រួល។